មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយឈ្មោះ ទួន រី ភេទស្រី អាយុ៥៩ឆ្នាំ

**មុខងារសម័យខ្មែរក្រហមៈ «ពេទ្យយោធាកងពល៩២០»**

**ស្រុកកំណើតនៅភូមិតាដែក ឃុំចើងដើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ**

**រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ សុខ វណ្ណៈ**

**០១:២១:១៨**

**៣២ទំព័រ**

វណ្ណៈ: ចឹងមីងខាងខ្ញុំមកនេះ គឺចង់រឿងរ៉ាវដែលបងប្អូនយើងធ្លាប់ឆ្លងកាត់សម័យតស៊ូមកដល់ឥឡូវ ខ្លះនៅខេត្តផ្សេងៗមករស់នៅតាមជាយដែនហ្នឹង ដោយសារថាមានបញ្ហាអីខ្លះកើតឡើងបាន យើងមកដល់នេះ ហើយយើងមិនបានត្រឡប់ទៅរស់នៅក្នុងស្រុកកំណើតវិញ ដោយសារថា មានមូលហេតុអី ហើយជីវភាពសព្វថ្ងៃយ៉ាងម៉េច ចឹងចង់សួរពីការរស់នៅនិងទំលាមទំលាប់ និងរឿងរ៉ាវផ្សេងៗទៀត ។

រី: ចាស ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ណែនាំខ្លួនដែលថាខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំមកហ្នឹង គឺចង់ដឹងរឿងរ៉ាវដែលខ្ញុំបាននិយាយមិញចឹង ហើយបទសម្ភាសខ្ញុំជាមួយមីងខ្ញុំសុំអនុញ្ញាតិពី មីងយកទៅប្រើការឲ្យក្មេងៗជំនាន់ក្រោយបានដឹងព្ទមីងមិនថាអីទេ?

រី: ចាស ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ មីង មីងឈ្មោះអីដែរ?

រី: ទួន រី ។

វណ្ណៈ: មីងអាយុប៉ុន្មានហើយ?

រី: ខ្ញុំអាយុជិត៦០ហើយ ។

វណ្ណៈ: អាយុប៉ុន្មានទៅ?

រី: អាយុ៥៨-៥៩ជឹងឆ្នាំនេះ ។

វណ្ណៈ: ចឹងអាយុ៥៩?

រី: ចាស ។

វណ្ណៈ: ចឹងប្ដីមីងឈ្មោះអី?

រី: ឈ្មោះ វុន ភឹម ។

វណ្ណៈ: ចឹងអាយុគាត់ប្រហែលជាប៉ុន្មាន?

រី: មើលអាយុគាត់៥០ប៉ុន្មាន មើលខ្ញុំ៥៩គាត់៥៧ ។

វណ្ណៈ: ចឹងគាត់ប្អូនវិញ?

រី: គាត់ប្អូន ។

វណ្ណៈ: ចឹងកូនមីងរាល់ថ្ងៃមានប៉ុន្មាន?

រី: កូនខ្ញុំមាន៦នាក់ ។

វណ្ណៈ: ស្រីប៉ុន្មាន?

រី: ស្រី២ប្រុស៤ មានគ្រួសារមួយតែប្តីស្លាប់ប្រាំងមិញបាត់ហើយ ។

វណ្ណៈ: ប្តីស្លាប់ដោយសារអី?

រី: ស្លាប់ដោយសាររន្ទះបាញ់ប្រាំងមិញ ទៅដាំដំឡូងនៅចម្ការបាញ់អីចម្ការនោះឯងខែ៤ថ្ងៃ២៨ ចូលឆ្នាំហើយ ។

វណ្ណៈ: ចឹងទើបការបានមួយឆ្នាំទេ?

រី: ចាស! បានកូនមួយហើយ កូនមួយខួបកន្លះហើយឪស្លាប់ ។

វណ្ណៈ: ចឹងដូចជានៅក្នុងគ្រួសារមីងហ្នឹង រៀបការហើយប៉ុន្មាននៅក្នុងបន្ទុកប៉ុន្មាន?

រី: ទើបការបានមួយហ្នឹង ហើយដល់ប្តីចឹងទៀតវានៅដដែលហ្នឹងវានៅជាមួយដដែលផ្ទះសំបែង ដដែលហ្នឹង ។

វណ្ណៈ: ចឹងសព្វថ្ងៃហ្នឹងមីងប្រកបមុខរបរអីដែរ?

រី: រាល់ថ្ងៃហ្នឹងប្រកបមុខរបរធ្វើស្រែចម្ការហ្នឹងហើយស្រុកយើងនេះ ។

វណ្ណៈ: ចឹងមីងខ្ញុំចង់សួរពីភូមិកំណើតមីង មីងនៅភូមិអី?

រី: ខ្ញុំនៅភូមិតាដែត ។

វណ្ណៈ: ឃុំ?

រី: ឃុំចើងដើង ។

វណ្ណៈ: ស្រុក?

រី: ស្រុកបារាយណ៍ ។

វណ្ណៈ: ខេត្តកំពង់ធំ?

រី: ចាស ។

វណ្ណៈ: ចឹងសព្វថ្ងៃនៅភូមិអីដែរ?

រី: សព្វថ្ងៃនៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

វណ្ណៈ៖	ឪពុកមីងឈ្មោះអីដែរ?

រី៖	ឪពុកខ្ញុំឈ្មោះ ហៀង ។

វណ្ណៈ៖	ចឹងស្គាល់ត្រកូលគាត់ទេ?

រី៖	ត្រកូលគាត់ស្អីទេ ម៉ែមីងហៀង យាយមិនដឹងឈ្មោះអីទេ ត្រកូលពុកត្រកូលម៉ែមិនដឹងឈ្មោះអីទេ ដាក់ថា ផន ទទេ ។

វណ្ណៈ៖	ចឹងម្ដាយឈ្មោះ ផន ។

រី៖	ផន "ផ" ។

វណ្ណៈ៖	ចឹងមីងមានបងប្អូនបង្កើត?

រី៖	បងប្អូនមាន៧នាក់ ស្លាប់អស់ហើយពីរបីនាក់ ចូលបប្រើយើងមុនដាច់ខ្ជនេះ ប្អូនខ្ញុំរាល់ថ្ងៃនៅតែ៤ទេ ។

វណ្ណៈ៖	ចឹង៧នាក់ហ្នឹងមានស្រីប៉ុន្មាន?

រី៖	មានស្រី៣ ។

វណ្ណៈ៖	ចឹងប្រុស៤?

រី៖	ចាស ។

វណ្ណៈ៖	ចឹងបងទី១ ឈ្មោះដែរ?

រី៖	ដឹងឈ្មោះអីទេ ខ្ញុំនៅតូចៗ ដែលអត់ដឹងខ្ញុំធំឡើងមិនដែលបានសួរនាំម៉ែអីដូចថាស្លាប់ៗ ។

វណ្ណៈ៖	ចឹងទី២?

រី៖	ទី២ខ្ញុំ ។

វណ្ណៈ៖	ទី៣?

រី៖	ទី៣ប្អូនខ្ញុំឈ្មោះ ហេង ។

វណ្ណៈ៖	ទី៤?

រី៖	ទី៤ឈ្មោះ ហុន ។

វណ្ណៈ៖	ទី៥?

រី៖	ទី៥ ឈ្មោះ ភួង ប្អូនស្រីខ្ញុំនៅថ្នល់ក្រហមយើងនេះ ។

វណ្ណៈ៖	ទី៦?

រី៖	ទី៦ ឈ្មោះ ហាង ។

វណ្ណៈ៖	ទី៧?

រី៖	ទី៧ ឈ្មោះ ហៀក ។

វណ្ណៈ: ចឹងស្លាប់អស់៣នាក់ហ្នឹង ស្លាប់ដោយសារអី?

វី: បងគេនោះខ្ញុំនៅតូចៗដែលអត់ដឹង បែបឈឺហ្នឹងស្លាប់បាត់ទៅខ្ញុំកើតមកមិនបានឃើញដែរ ឮថាស្លាប់បងៗ ។

វណ្ណៈ: ចឹងកាលពីនៅតូចមីងរៀនបានត្រឹមណាដែរ?

វី: រៀនបានតិចតួចសាលាអក្ខរកម្មក្នុងភូមិសាលាយើងខ្ញុំរៀបដែលតែរៀនបានតិចតួចនៅផ្ទះវាលំបាកពេកក៏មិនបានរៀនបានវែងឆ្ងាយទេ ។

វណ្ណៈ: ចឹងរៀនសាលាបឋមសិក្សាណា?

វី: រៀនសាលាបឋមសិក្សាយើងចឹងដែលតែខ្ញុំរៀនបានតិចមិនដឹងថ្នាក់ទីប៉ុន្មានគេទេ ។

វណ្ណៈ: រៀនកាលពីដើម?

វី: ចាស!ពីមុនហ្នឹង ។

វណ្ណៈ: រៀនបានប៉ុន្មានឆ្នាំ?

វី: មិនដឹងបានប៉ុន្មានឆ្នាំទេ ។

វណ្ណៈ: ពីដើមគេរាប់ពីថ្នាក់ទី១២ចុះមក១១ចឹង?

វី: ចាស!ខ្ញុំរៀនបានត្រឹមថ្នាក់ទី១២ហ្នឹងឯងខ្ញុំនោះ ។

វណ្ណៈ: ចឹងរៀនបានតែមួយឆ្នាំទេ?

វី: ចាស!មួយឆ្នាំពីរឆ្នាំដែលវាឌុបថ្នាក់ ។

វណ្ណៈ: ចឹងមីងចេះមើលអានបានទេ?

វី: មើលបានតើ ខ្ញុំសរសេរបានកើតខ្លះដែរ ខ្ញុំរៀនហ្នឹងគេយើងពីដើមនោះគេថា ខ្ញុំរៀនបានតែមួយឆ្នាំទេ គេថាឡើងដល់ថ្នាក់ទី៩កាលហ្នឹង មើលខ្ញុំថ្នាក់ទី១២ថ្នាក់១១បានទៅថ្នាក់ទី៩កាលនោះខ្ញុំរៀនបានតែប៉ុណ្ណឹងឯងក៏ ខ្ញុំសព្វថ្ងៃសរសេរកើតហើយតែពាក្យជ្រៅៗខ្ញុំមិនចេះ ។

វណ្ណៈ: ចឹងនិយាយពិតប្រាកដទៅរៀនត្រឹមថ្នាក់ទី១២ហ្នឹងឬមួយឡើងដល់ថ្នាក់ទី៩ដែរ?

វី: អត់ទេ អត់បានទៅដល់ទេ ។

វណ្ណៈ: ចឹងកាលហ្នឹងរៀននៅសាលាអីគេ?

វី: សាលាយើងធ្វើចឹង ។

វណ្ណៈ: សាលាតែមានឈ្មោះសាលា?

វី: សាលាអីទេ ខ្ញុំនៅក្មេងៗខ្ញុំមិនបានចាប់អារម្មណ៍ទេ មិនដឹងជាសាលាអី កាលហ្នឹងសាលាពណ្ណរាយ គេហៅវត្តពណ្ណរាយនៅជិតវត្តហ្នឹងឯងភូមិខ្ញុំហ្នឹង គេហៅសាលាពណ្ណរាយចឹង ។

វណ្ណៈ: ចឹងយ៉ាងម៉េចបានមីងឈប់រៀន?

រី៖ កាលដែលខ្ញុំឈប់រៀនកាលនោះឃើញពុកម៉ែលំបាកពេក ធ្វើស្រែចម្ការអីប្អូននៅតូចៗដល់ឃើញគាត់លំបាកពេកទៅក៏ឈប់ទៅ ឈប់ហ្នឹងមិនមែនឈប់និងនេះទេខ្ញុំឈឺ ឈឺកើតហើមជើងឈប់យូរណាស់ ជើងកាលហ្នឹងមិនដឹងកើតអីទេ គាំបិតពូថៅវាមុតចំនេះឯងសាឡាក់ដល់ពាល់ថ្ងៃ ។

វណ្ណៈ៖ មីងឈប់រៀននៅឆ្នាំណាដែរ?

រី៖ ខ្ញុំមិនដឹងឆ្នាំឈប់ មិនដឹងថាឆ្នាំប៉ុន្មានទេ ។

វណ្ណៈ៖ មីងឈប់ហ្នឹងនៅពេលរដ្ឋប្រហារឬឈប់មុនរដ្ឋប្រហារ?

រី៖ ឈប់មុនរដ្ឋប្រហារទៀត ។

វណ្ណៈ៖ ចឹងកាលឆ្នាំរដ្ឋប្រហារឆ្នាំ១៩៧០ មីងដឹងទេ?

រី៖ ដឹងតើ រត់ ។

វណ្ណៈ៖ រត់ទៅខាងណាវិញ?

រី៖ រត់មកខាងលើនេះ គេហៅស្ទឹទេ អន្លង់ថ្មនេះមកលើផ្លូវមកលើបាក់ស្នា រត់ទៅលើវិញ ។

វណ្ណៈ៖ យ៉ាងម៉េចបានរត់?

រី៖ រត់កាលហ្នឹងនៅក្មេងៗ ដែលគេថាយៀកកុងចូលៗខ្ញុំមិនស្គាល់នៅក្មេងៗ ។

វណ្ណៈ៖ មីងកាលហ្នឹងអាយុប្រហែលជាប៉ុន្មានហើយ?

រី៖ ដឹងអាយុប៉ុន្មានឆ្នាំ៧០ ហ្នឹង មិនដឹងជាអាយុប៉ុន្មាន ។

វណ្ណៈ៖ តាមមើលជាង១០ឆ្នាំ?

រី៖ ប្រហែលជា១៤-១៥ ហើយដឹងខ្ញុំរត់ហ្នឹង ព្រោះអីខ្ញុំចូលបដិវត្ត ចូលកងនារីអាយុ១៧-១៨ ហ្នឹង ។

វណ្ណៈ៖ ចឹងក្រោយពីមានរដ្ឋប្រហារហើយ មីងមានដឹងថាមានការទម្លាក់គ្រាប់បែកមានទេ?

រី៖ មានតើ ខ្ញុំរត់ហ្នឹងហើយមានទម្លាក់គ្រាប់បែកនៅកំពង់ថ្ម រត់ភូមិខ្ញុំត់ខ្ចាយទៅនៅភូមិគេ ។

វណ្ណៈ៖ ឆ្នាំណាដែលមានទម្លាក់គ្រាប់បែក?

រី៖ ឆ្នាំ១៩៧០ ហ្នឹងដឹង ។

វណ្ណៈ៖ ចឹងរដ្ឋប្រហារហើយភ្លាមហ្នឹង?

រី៖ ចាស!ឆ្នាំ៧០-៧១ ហ្នឹងឯងខ្ញុំរត់នោះ នៅក្មេងៗ ដែលមិនបានចាប់អារម្មណ៍គិតដឹងថា ខែណាឆ្នាំណា ។

វណ្ណៈ៖ ចឹងមីងមានដឹងថា គ្រាប់បែកខាងណាជាអ្នកទម្លាក់?

រី: ដឹងខាងណាកាលនោះគេថាអាមេរិចៗ ខ្ញុំមិនដឹងដែរ តែកាលដែលតស៊ូរត់ហ្នឹងខ្ញុំឃើញទាហានឃើញកាន់កាំភ្លើងឃើញយួនហ្នឹងឯងនៅតាមភូមិតាមអី មកនៅមិនដឹងជាវាយជាមួយស្អី ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ: ចឹងកាលហ្នឹងមានយួនចូលមកដែរ?

រី: ចាស!មានយួនចូលមកហើយ ។

វណ្ណៈ: ចឹងកាលហ្នឹងមីងអត់បានដឹងថា យួនចូលមកសហការជាមួយខ្មែរក្រហមទេ?

រី: ចាស!អត់ដឹងដែលកាលហ្នឹងនៅក្មេងៗតែគ្រាន់តែឃើញចឹង គេហៅយៀកកុងៗមិនស្គាល់ផង ។

វណ្ណៈ: កាលហ្នឹងខាងខ្មែរក្រហមគេហៅថា ខ្មែររំដោះជាតិអីចឹង?

រី: ចាស ។

វណ្ណៈ: គេមិនហៅខ្មែរក្រហមទេ?

រី: ចាស ។

វណ្ណៈ: ចឹងកាលហ្នឹងមានការសហការជាមួយយួន?

រី: ចាស ។

វណ្ណៈ: ចឹងដល់ពេលឆ្នាំណា មីងបានចូលជាបដិវត្តធ្វើជាយុទ្ធនារីអីហ្នឹងគេ?

រី: ខ្ញុំបានចូលនៅឆ្នាំ១៩៧៣ហ្នឹង ថ្ងៃទី៥ដឹងខែ១០ ភ្លេចដែរ ។

វណ្ណៈ: ចឹងកាលដែលមីងចូលទៅហ្នឹង មានគេមកបង្ខំឲ្យចូលឬមួយមីងស្ម័គ្រចិត្តចូលទេ?

រី: ហ្នឹងដូចថាចង់ខ្លួនឯងចូលទៅហ្នឹង មិនមែនគេរុញច្រានឬមួយឈឺចាប់អីទេ ខ្ញុំនៅក្មេងៗមិនសូវដឹងដែរ កាលនោះមានហាត់សិល្បៈហាត់អីនោះ ។

វណ្ណៈ: ចឹងចូលទៅដំបូងហាត់សិល្បៈ?

រី: ចាស!ចូលទៅដូចថាសប្បាយ មានដឹងថាចូលទៅហ្នឹងតស៊ូអីមិនបានដឹងទេ កាលហ្នឹង ។

វណ្ណៈ: ចឹងកាលចូលទៅដំបូងហ្នឹងមានគ្នាប៉ុន្មាននាក់ដែលកាលហ្នឹង?

រី: នៅភូមិខ្ញុំចូលពីរបីនាក់នោះ ដល់ពេលគេចាត់តាំងខ្ញុំទៅតាមកងនារីទៅ ខ្ញុំនៅខាងកងនារីគេទៅផ្ទះវិញអស់ទៅ នៅតែខ្ញុំ ខ្ញុំអត់ទៅ ។

វណ្ណៈ: ខ្លះគេទៅផ្ទះវិញ?

រី: ខ្លះគេទៅផ្ទះវិញ ខ្ញុំអត់ទៅ ។

វណ្ណៈ: ចឹងកាលមីងចូលដំបូងនៅឆ្នាំ១៩៧៣គេឲ្យមីងនៅត្រឹមណា?

រីៈ គេឲ្យនៅត្រឹមឃុំ នៅភូមិជិតត្រឹមសង្កាត់ គេនោះមិនដឹងហៅឃុំហៅតែសង្កាត់ៗ នៅត្រឹមឃុំ ខ្ញុំធ្វើពេទ្យកាលហ្នឹង ។

វណ្ណៈៈ ចឹងចូលដំបូងធ្វើពេទ្យ?

រីៈ ចាស! គេរើសខ្ញុំឲ្យធ្វើពេទ្យ មុនដំបូងពេទ្យភូមិ ។

វណ្ណៈៈ ចឹងសិល្បៈក្រោយទៀតទេ ចូលទៅដំបូងភ្លាមៗគេឲ្យមីងធ្វើអី?

រីៈ ចូលទៅនៅហាត់សិល្បៈទេ តែក្នុងចិត្តខ្ញុំដែលចូលទៅមិនដឹងថាគេរើសទៅចូលពេទ្យអីទេ ដឹងថាចូលទៅនៅកន្លែងកងនារីហ្នឹង គេរាំគេរែកគេហាត់សិល្បៈអី តែក្នុងចិត្តខ្ញុំនេះមិនមែនថាចូលគេរើសធ្វើអីៗអត់ដឹង ដល់ចូលទៅដល់នោះបានគេរើសធ្វើពេទ្យឈប់នៅកន្លែងកងសិល្បៈណាស់ ។

វណ្ណៈៈ ចឹងចូលទៅដល់ដំបូងនៅកន្លែងកងសិល្បៈមានបានរាំអីទេ?

រីៈ បានរាំបានរែកអីទេ ក្នុងចិត្តខ្ញុំទេ នឹកឃើញចង់ចូលទៅទេ ចង់ទៅខាងហ្នឹងសប្បាយតែចូលទៅមានបានរាំរែកអីអត់ទេ ចូលទៅដល់ក្នុងឃុំហ្នឹងទៅគេរើសធ្វើពេទ្យអីនៅឃុំហ្នឹង ។

វណ្ណៈៈ ចឹងពេទ្យឃុំ?

រីៈ ចាស ។

វណ្ណៈៈ ចឹងកាលហ្នឹងមីងធ្វើពេទ្យយ៉ាងម៉េច មុខវិជ្ជាពេទ្យត្រូវការអ្នករៀនសូត្របានខ្ពង់ខ្ពស់ចឹងមីងម៉េចបានគេឲ្យមីងធ្វើពេទ្យបាន?

រីៈ កាលហ្នឹងគេឲ្យធ្វើពេទ្យហ្នឹង គេឲ្យមករៀនបើកវគ្គអីចឹង ថាឲ្យមករៀនចឹងមកយើងទៅមើលប្រជាជននៅក្នុងភូមិ កាលហ្នឹងមានបីនាក់សហការគ្នាប្រជាជនឈឺស្កាត់គ្រុនរងាអី យើងដើរមើលឲ្យថ្នាំសង្កូវអីចឹងណាស់ ។

វណ្ណៈៈ បាទ ។

រីៈ មិនមែនធំដុំ បើសិនជាឈឺធ្ងន់គេបញ្ជូនតាមដំណើរចឹងទៅ ។

វណ្ណៈៈ មីងមានចេះចាក់ថ្នាំអីទេ?

រីៈ ពីមុនខ្ញុំចេះតើ តែដល់ឥឡូវល្ងិតទៅវាខ្វាចមិនសូវហ៊ានមើលចេះចាក់កើត រឿងថ្នាំសង្កូវកូនចៅអីគ្រាន់បានដឹងខ្លះ គេរើសធ្វើពេទ្យតែក្នុងចិត្តខ្ញុំនឹកឃើញថា ខ្លួនមើលអក្សរលើអំពូលថ្នាំអីអត់កើត មិនចេះបារាំងមិនចេះអង់គ្លេសអី ក៏ខ្ញុំឈប់ទៅ ក៏គេរើសទៅខាងកងនារីទៅ ។

វណ្ណៈៈ ចឹងកាលដែលមកបង្រៀនពេទ្យហ្នឹងពីណាមកបង្រៀន?

រីៈ មកបង្រៀនហ្នឹងនៅខាងឃុំដឹង ដូចថាមេមន្ទីរពេទ្យហ្នឹង ។

វណ្ណៈៈ អ្នកបង្រៀនហ្នឹងឈ្មោះអីទៅ?

រីៈ	គ្រូបង្រៀនហ្នឹងឈ្មោះ ផល ពូហ្នឹងនោះនៅកន្លែងពេទ្យ ប្រធានពេទ្យគេឈ្មោះផល តែឥឡូវមិនដឹងជាដល់ណាណីអស់ហើយ ។

វណ្ណៈៈ	ស្រី?

រីៈ	ប្រុស កាលហ្នឹងបើកវគ្គដែលរៀនច្រើនគ្រប់ភូមិស្រុក ។

វណ្ណៈៈ	ពេទ្យនៅក្នុងឃុំហ្នឹងមានគ្នាប៉ុន្មាននាក់?

រីៈ	មានច្រើនដែលមានគ្នាប្រហែលជា៥០ទៅ៦០នាក់អីទៅ ពេលរៀនបើកវគ្គហ្នឹង ។

វណ្ណៈៈ	ចឹងកាលហ្នឹងប្រជាជនគាត់ឈឺអីខ្លះទៅ?

រីៈ	ប្រជាជននៅតាមផ្ទះមានតែផ្ដះសាយមានតែគ្រុនចាញ់អីហ្នឹងឯងមានតិចតួច ។

វណ្ណៈៈ	ហ្នឹងនៅឆ្នាំ១៩៧៣-៧៤?

រីៈ	ចាស!៧៣-៧៤ ។

វណ្ណៈៈ	ចឹងកាលហ្នឹងគណៈស្រុកគណៈតំបន់អីមីងស្គាល់ទេ?

រីៈ	អត់ស្គាល់ទេ ឥឡូវភ្លេចអស់ហើយវាយូរពេកហើយ ។

វណ្ណៈៈ	ចឹងនៅពេទ្យរយៈពេលប៉ុន្មានដែរ?

រីៈ	ខ្ញុំនៅបានតែរយៈពេលមួយឆ្នាំ ។

វណ្ណៈៈ	ចឹងឆ្នាំ៧៣-៧៤?

រីៈ	ឆ្នាំ៧៣-៧៤ ខ្ញុំគេរើសទៅធ្វើកងនារី ។

វណ្ណៈៈ	កងនារីហ្នឹងធ្វើអីទៅ?

រីៈ	ខាងកងនារីហ្នឹង ជីកប្រឡាយលើកទំនប់អីហ្នឹង ។

វណ្ណៈៈ	ចឹងកងចល័តនារី?

រីៈ	ចាស ។

វណ្ណៈៈ	ចឹងកងនារីហ្នឹងចូលជាកងនារីស្រុកហើយឬមួយយ៉ាងម៉េច?

រីៈ	កងនារីនៅខាងស្រុកហ្នឹងឯង ខ្ញុំកាលហ្នឹងទៅខាងអន្លង់ថ្ម បាក់ស្នានោះគេយកទៅជីកប្រឡាយលើកទំនប់បានរយៈពេលប៉ុន្មានទេ មិនបានមួយឆ្នាំទេ ទៅកន្លែងកងនារីគេផ្លាស់កន្លែងទៅទៀត ។

វណ្ណៈៈ	ទំនប់ហ្នឹងឈ្មោះអីដែរ?

រីៈ	មិនដឹងហៅស្អីទេ តែនៅភូមិបាក់ស្នាហ្នឹង នៅលើកទំនប់ជីកប្រឡាយ ។

វណ្ណៈៈ	មានគ្នាច្រើនទេ?

រីៈ	មានច្រើនរាប់រយនាក់កងនារីច្រើន ។

វណ្ណៈ៖ ចឹងកាលហ្នឹងម៉េចបានមានកងចល័តនារីលើកទំនប់អីហ្នឹង ព្រោះអីឆ្នាំ៧៣-៧៤មិនទាន់វាយឈ្នះផង ម៉េចបានជាទៅលើកចឹងកើត នៅមានទាហានលន់ នល់ នៅមាននៅឡើយហ្នឹង មឹងអាចប្រទូរំឆ្នាំ១៩៧៥ហើយទេ បានជាមានកងនារីកងអី គេលើកទំនប់អីបានប្រជាជនហូបបាយរួមបាន ព្រោះនៅចន្លោះហ្នឹងកំពង់តែមានសង្គ្រាម?

រី៖ ៧០ប៉ុន្មានកងចល័តបាយរួមក្នុងភូមិខ្ញុំអត់មានបាននៅផង មិនដឹងជា៧០ប៉ុន្មាន ។

វណ្ណៈ៖ ចឹងនៅពេលខ្មែរក្រហមឈ្នះមានបាយរួមអីហ្នឹងចាប់ពីឆ្នាំ១៩៧៥ទៅ បានប្រជាជនគេឲ្យទៅធ្វើស្រែចម្ការលើកទំនប់ជីកប្រឡាយកាលហ្នឹង តាំងពីឆ្នាំ១៩៧៥-៧៦-៧៧ឡើងរហូត បើថាឆ្នាំ១៩៧៣-៧៤ហ្នឹងខ្ញុំគិតថាមិនទាន់លើកបានទេ ព្រោះកំពង់តែមានសង្គ្រាមនៅវាយជាមួយទាហានលន់ នល់ ដដែលហ្នឹង មឹងអាចប្រទូរំឆ្នាំ៧៣-៧៤ហ្នឹង មឹងកំពង់តែមានចលនាអីផ្សេង ចឹងបើធ្វើទំនប់ម៉េចធ្វើបាន បើកាលហ្នឹងកំពង់តែច្បាំងគ្នាហ្នឹង យើងមានពេលណាទៅធ្វើទំនប់កើត?

រី៖ ឆ្នាំ៧៣-៧៤ ព្រោះអីនៅអន្លង់ថ្មហ្នឹងខ្ញុំ៧៣គេរើសទៅកងនារីហ្នឹងវាយនៅសមរភូមិ ។

វណ្ណៈ៖ ចឹងមឹងធ្លាប់ទៅវាយដែលចឹង?

រី៖ ទៅកាលហ្នឹងគ្រាន់តែដញ្ជូនគ្រាប់អីទេ ។

វណ្ណៈ៖ ចឹងត្រូវ?

រី៖ ចាស ។

វណ្ណៈ៖ បើថាឆ្នាំ៧៣-៧៤ដញ្ជូនគ្រាប់អីត្រូវ ដល់លើកទំនប់មិនអាចទេ?

រី៖ មើលចាំមើលខ្ញុំនិយាយ ចាប់ពីខ្ញុំឆ្នាំ៧៥ដាច់ភ្នំពេញ ។

វណ្ណៈ៖ បាទ ។

រី៖ ៧៥ដាច់ភ្នំពេញ ខ្ញុំចុះមកនៅខាងរតនគិរីមណ្ឌលគិរីវិញ អត់មានដែលធ្វើអីទេ អត់មានលើកទំនប់ជីកប្រឡាយអីវាអត់ អត់ដែលទេហ្នឹង បើកាលពីមុនហ្នឹង ខ្ញុំនៅកងនារីចេញពីកន្លែងពេទ្យហ្នឹង ខ្ញុំលើកមែន ។

វណ្ណៈ៖ ចឹងមឹងមានដឹងថាដាច់ភ្នំពេញហើយនៅ?

រី៖ នៅមិនទាន់ដាច់ទេ ។

វណ្ណៈ៖ ចឹង?

រី៖ មិនទាន់ដាច់ទេ ។

វណ្ណៈ៖ ចឹងមានលើកទំនប់បានដែរ?

រី៖ លើកបាននៅកងនៅសង្កាត់នោះខ្ញុំចេញពីកន្លែងកង ។

វណ្ណៈ	ចឹងពេលណាដែលមីងនិយាយថា ជញ្ជូនគ្រាប់អីហ្នឹង?

រី:	ពេលហ្នឹងឆ្នាំ៧៤-៧៥ ឆ្នាំ១៩៧៥យើងដាច់ ឆ្នាំ៧៤-៧៣អីហ្នឹង៧៤ហ្នឹងឯងខ្ញុំទៅកន្លែងកងនារីគេវាយនៅកំពង់ធំគេវាយនៅកោះស្អឹគេទេ ច្រើនណាស់វាយកំពង់ធំអីខ្ញុំនៅថ្នល់ធំ ។

វណ្ណៈ	មីងនៅជញ្ជូនគ្រាប់ប៉ុយ៉ាងម៉េច?

រី:	ខ្ញុំនៅជញ្ជូនគ្រាប់ឲ្យគេ កងនារី ខ្ញុំដើរនៅច្រើនកន្លែងណាស់ខ្ញុំមិនស្គាល់ទេ ។

វណ្ណៈ	ចឹងកាលហ្នឹងវាយនៅខាងកំពង់ធំអី?

រី:	ចាស ។

វណ្ណៈ	មីងកាលហ្នឹងមានដឹងថា វាយជាមួយពួកណា?

រី:	ដឹងវាយពួកណាដឹង បើដាច់ភ្នំពេញមកឃើញខ្មែរក្រហមយើងនៅក្រុងភ្នំពេញ ព្រោងព្រាតវាយខាងពួកណាខ្ញុំមិនសូវដឹងវាយខាងណាហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងមីងអត់ដឹងថាវាយជាមួយទាហាន លន់ នល់ អីទេ?

រី:	កាលហ្នឹងគេថា លន់ នល់ តែមិនដឹងយ៉ាងម៉េចដឹងខាងណាជាមួយយួនក៏អី ។

វណ្ណៈ	កាលហ្នឹងវាយជាមួយទាហានលន់ នល់ ហ្នឹងហើយ?

រី:	ដឹងទាហានលន់ នល់ ដឹងអី ។

វណ្ណៈ	ចឹងពេលវាយបែកភ្នំពេញឆ្នាំ១៩៧៥មីងមានបានចូលដល់ភ្នំពេញទេ?

រី:	ខ្ញុំបានចូលដែរ ខ្ញុំបានចូលដល់ ។

វណ្ណៈ	ចឹងកាលហ្នឹងមីងមានដឹងថា នៅជាមួយកងពលពីណា?

រី:	ខ្ញុំនៅកងពលខ្ញុំគេហៅកងពល៩២០ ។

វណ្ណៈ	ពីណាប្រធានកងពល?

រី:	ប្រធានកងពលឈ្មោះ តាសាន ។

វណ្ណៈ	អាហ្នឹងពេលទៅខាងមណ្ឌលគិរីហើយទេ បានមានឈ្មោះកងពល៩២០ហ្នឹង?

រី:	អត់ទេ មានឈ្មោះតាំងពីនៅកងនារីត្រៀមតាំងពីជញ្ជូនគ្រាប់មក ហ្នឹងគេហៅកង៩២០ចឹងដល់ពេលចូលភ្នំពេញ ។

វណ្ណៈ	ប្រធានកងពលឈ្មោះអីសាន?

រី:	អត់ដឹង ឈ្មោះអីផង ។

វណ្ណៈ	ចឹងអនុតាសានហ្នឹងទេ?

រី:	ខ្ញុំអត់ស្គាល់អស់ទេ ។

វណ្ណៈ	ចឹងកាលនៅវាយគ្នាហ្នឹង មីងមានបានតួនាទីជាប្រធានវរៈស្អីហ្នឹងគេដែរ?

រីៈ អត់ទេ បានក្រុមអីហ្នឹង ។

វណ្ណៈៈ ចឹងបានត្រឹមប្រធានក្រុម?

រីៈ ចាស ។

វណ្ណៈៈ ចឹងដែលវាយគ្នាជាមួយទាហានលន់ នល់ ហ្នឹងមីងមានដឹងថាពេលហ្នឹងមានមនុស្សស្លាប់ច្រើនទេ?

រីៈ ស្លាប់ច្រើនដែរ ព្រោះអីខ្ញុំអ្នកសែងស្នែង ជញ្ជូនគ្រាប់ផង ត្រៀមស្នែងផង អ្នករបួសគេយកមកពីមុខតាមខ្សែត្រៀមតាមតៗគ្នាមកយកទៅក្រោយវិញ មិនសមនឹកឃើញថា ដល់មកនៅស្រួលចឹងមកនឹកឃើញមិនសមទេ ស្រីៗសោះទៅនៅចឹង ។

វណ្ណៈៈ ចឹងកាលហ្នឹងមីងមានការភ័យខ្លាចដែរ?

រីៈ ចាស!ភ័យខ្លាចគ្រាប់អីមកខ្លាច យប់ឡើងមានគិញប្រឡំ ភ្លែលូ ទីទុយយំ ខ្លាចនៅសុទ្ធតែស្រីៗ ស្រីៗគេដាក់ខ្សែត្រៀមឆ្ងាយៗដែរ ប្រហែលមួយនាក់ចម្ងាយពី៥០ទៅ៦០ម៉ែត្រអីឆ្ងាយដែលហ្នឹង ដូចថាម្ខាងអូរទៅខាងនោះអីមួយទៅ ឆ្ងាយពីគ្នា បើសិនមានអ្នករបួសមកច្រើនចឹង អ្នកនៅរបួសៗហ្នឹងបបរបាយអីឲ្យហូបទៅសែងតែអ្នកធ្ងន់ៗទៅមុន យកទៅក្រោយបណ្តោះៗទៅយកទៅហើយ មានគិញមកប្រឡំធ្វើបាបទៅយប់ប្រលប់ខ្លាចស្រីៗ សុទ្ធតែស្រីៗ ដល់ដាច់ភ្នំពេញទៅស្រួលនឹកឃើញអើយ នៅផ្ទះបើថាចេះមិនមកទេ កាលហ្នឹងមិនទាន់ចេះគិត ។

វណ្ណៈៈ បាទ ។

រីៈ កាលហ្នឹងមកដាច់ពីម៉ែឪ ម៉ែឪស្លាប់ក៏មិនទាន់ដង្ហើមមិនបានដឹងមិនបានឃើញ រហូតមកដល់សព្វថ្ងៃទៅ ។

វណ្ណៈៈ ចឹងកាលហ្នឹងដាច់ភ្នំពេញភ្លាម មីងបានចូលដល់ភ្នំពេញនៅថ្ងៃទី១៧មេសាហ្នឹងតែម្តងឬមួយយ៉ាងម៉េច?

រីៈ ចូលដល់ភ្នំពេញដាច់មួយថ្ងៃហ្នឹងខ្ញុំចូលដល់ ខ្ញុំកាលហ្នឹងនៅទួលគោក ។

វណ្ណៈៈ ចឹងមីងចូលដល់ថ្ងៃទី១៧មេសាហ្នឹងតែម្តង?

រីៈ ចាស ។

វណ្ណៈៈ ចូលដល់ម៉ោងប៉ុន្មាន?

រីៈ ខ្ញុំចូលទៅល្ងាចដែលហើយ យប់ម៉ោង៤ទៅ៥ល្ងាចដល់កន្លែង ។

វណ្ណៈៈ ចឹងកាលហ្នឹង មីងមានបានឃើញប្រជាជនកំពង់តែជម្លៀសចេញទេពេលហ្នឹង?

រីៈ ឃើញ យន្តហោះ ហោះពេញហ្នឹង ភ័យជិតងាប់ ។

វណ្ណៈ	ចឹងមានយន្តហោះទៀត?

រី:	ចាស!មានយន្តហោះក្រឡឹងស្រែក ស្រែកឲ្យប្រជាជនចេញ ។

វណ្ណៈ	ចឹងយ៉ាងម៉េចស្រែកព្វបើបើកយន្តហោះចឹង?

រី:	ស្រែកព្វ បើគេស្រែទាបៗហ្នឹង គេស្រែកព្វកោកៗព្វដល់ក្រោមហ្នឹងឯង គេហោះទាបៗ ។

វណ្ណៈ	ចឹងខាងក្រោមនេះយើងចូលទៅមានប្រាប់ឲ្យប្រជាជនចេញដែលទេ?

រី:	ចាស!ប្រជាជនចេញខ្លះរែកខ្លះពុន ខ្លះស្លាប់នៅក្នុងមុងទៅទាំងមួយទាំងពីរប្តីប្រពន្ធ ប្រពន្ធក៏ឃើញ ។

វណ្ណៈ	យ៉ាងម៉េចបានស្លាប់?

រី:	ស្លាប់ពេលដែលគេវាយគ្នានោះ ខ្លះស្លាប់នៅពួកកងខ្ញុំដើររៀបចំ ដូចថាគេឲ្យដើររៀបផ្ទះតាមកងនារីនោះ ។

វណ្ណៈ	បាទ ។

រី:	ចូលទៅដល់គេឲ្យរៀបតាមផ្ទះ ខ្លះឃើញមនុស្សនៅស្លាប់ហ្នឹង ខ្លះឃើញម៉ែកូននៅប្តីរត់ទៅបាត់ទៅ អូយ!ឃើញវេទនាណាស់ គិតមើលទៅ ។

វណ្ណៈ	ចឹងកងមីង អត់មានទៅដល់ដេញគាត់សម្ងុតគាត់អីទេ?

រី:	អត់ទេ ខ្ញុំមិនបានដេញទេ បើមេៗមិនដឹងទេ បើចំណែកខ្ញុំកងនារីគ្រាន់តែចូលរៀបចំផ្ទះសំបែង ។

វណ្ណៈ	ចឹងពេលមីងទៅឃើញស្លាប់នៅក្នុងផ្ទះអីចឹង អាហ្នឹងស្លាប់ដោយត្រូវគ្រាប់ឬមួយស្លាប់ដោយសារអី?

រី:	ខ្លះឃើញត្រូវដែរ ត្រូវគ្រាប់ត្រូវផ្ទះអីចឹង ខ្លះនៅលើផ្ទះហ្នឹងប្តីទៅចោលកូនខ្ចីទៅមិនរួចអីចឹងខ្លះឃើញនៅលើផ្ទះចឹងឯង ។

វណ្ណៈ	ចុះធ្វើយ៉ាងម៉េចទៅអ្នកទាំងហ្នឹង?

រី:	អ្នកហ្នឹងយ៉ាងម៉េច ប្រជាជនគេបញ្ជូនយកទៅមិនដឹងជាទៅខាងណាមេៗខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ	ចឹងពេលមានអ្នកណាទៅមិនរួចមានឡានគេដឹកយកទៅទៀត?

រី:	ចាស!មេៗគេថាបញ្ជូនទៅតែមិនដឹងជាបញ្ជូនទៅខាងណា ខ្ញុំមិនបានដឹងដែរ ។

វណ្ណៈ	ចឹងកាលហ្នឹងមានស្លាប់អីដែរ ពេលចូលដល់ភ្នំពេញហ្នឹង?

រី:	ចាស!មាននៅក្នុងទីក្រុង តែខ្ញុំនៅត្រឹមទួលគោកទេ មិនបានចូលដល់ទីក្រុងភ្នំពេញធំមិនបានចូលដល់កងខ្ញុំនៅធ្វើការត្រឹមហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងកងនារីនៅផ្សេងកងបុរសនៅផ្សេង?

រី៖ ចាស! នៅផ្សេងគ្នា ហៅពូ ទាក់ទងគ្នាមិនបានទេ ។

វណ្ណៈ៖ ចឹងមានរយៈពេលប៉ុន្មានដែលអ្នករៀបចំឃើញខ្មោចយកទៅកប់ ពេលបោសសម្អាតហ្នឹងរយៈពេលប៉ុន្មានដែរ?

រី៖ យូរដែលឆ្នាំ៧៥ តែមិនខែប៉ុន្មានទេ ៧៥ហ្នឹងចូលទៅដល់ខែប៉ុន្មានទេ ឆ្នាំប៉ុន្មានទេបានចេញពីហ្នឹងមកនៅខេត្តមណ្ឌលគិរី ឆ្នាំ៧៥-៧៦ហ្នឹងនៅខ្ញុំនៅមិនបានកន្លះឆ្នាំទេនៅហ្នឹង ខ្ញុំនៅទួលគោកនោះ ដល់ពេលឲ្យទៅលេងតាមឃុំតាមស្រុកដល់ពេលទៅមិនបាននៅយូរណា គេថាយើងវាយក្រោយមកនេះ វាយជាមួយយួននេះ ។

វណ្ណៈ៖ ចឹងខ្ញុំចង់និយាយពីការបោសសម្អាតសិន ចឹងកាលហ្នឹងពួកមីងបានឃើញមនុស្សស្លាប់នៅក្នុងផ្ទះអីចឹងឆ្នាំ១៩៧៥ រំដោះហ្នឹងគឺយើងខ្មោចហ្នឹងជុតចោលឬមួយកប់ចោល?

រី៖ យកទៅកប់ជិតៗហ្នឹងដែរ ។

វណ្ណៈ៖ ចឹងយើងចេះតែធ្វើការបោសសម្អាតទៅ?

រី៖ ចាស! យើងបោសសម្អាតរៀបចំផ្ទះសំបែងទៅ ។

វណ្ណៈ៖ ចឹងពេលមីងដើរបោសសម្អាតហ្នឹងមានឃើញមាសប្រាក់អីទេ លុយកាក់អីទេ?

រី៖ ឃើញតែយើងយកមិនបាន យើងយកមកមេគេដកទៅ យើងមិនបានទុកដាក់ខ្លួនយើងទេ គេមិនឲ្យមាន ។

វណ្ណៈ៖ វិន័យតឹងតែងទេ?

រី៖ តឹងណាស់ គេថាមានមាសអីហ្នឹងគេមិនឲ្យពាក់មិនឲ្យអី បើបានដកយកទៅឲ្យមេ ខ្ញុំនៅតាមកងនារីយើងរគាន់តែរៀបចំ យើងយកមកអីមេគេដកទៅយកទៅណាមិនដឹង ។

វណ្ណៈ៖ ចឹងកាលមីងនៅហ្នឹងនៅក្នុងកងពល៩២០ដដែល?

រី៖ ចាស ។

វណ្ណៈ៖ ចឹងតាសានដឹកនាំដដែល?

រី៖ ចាស ។

វណ្ណៈ៖ ចឹងមីងមានដឹងថា មីងនៅក្នុងកងវរៈលេខប៉ុន្មាន វរសេនាតូចលេខប៉ុន្មាន?

រី៖ ខ្ញុំដឹងតែកងពល៩២០ គេហៅកង៩២០ចឹង ។

វណ្ណៈ៖ ចឹងគ្នាមីងនៅទួលគោកហ្នឹងមានគ្នាប្រហែលជាប៉ុន្មានរយនាក់?

រី៖ មានច្រើនដែរ កងពលហើយមានប៉ុន្មានទេ ។

វណ្ណៈ៖ ចឹងកងពលចូលម៉ឺននាក់ហើយ?

រី:	ចាស!ច្រើន ព្រោះអីនៅម្នាងម្នាក់ កងពលខាងតាសារឿន នោះមួយកងពល តាសារឿន កងពល៨០១ នៅម្នាងផ្លូវម្នាក់ ។

វណ្ណៈ:	ចឹងមីងមានដឹងថាមានប៉ុន្មានកងពលដែលចូលដល់ភ្នំពេញ?

រី:	ដឹងថាមានប៉ុន្មានគេថា កងពិសេស គេហៅកងពិសេសមិនដឹងជាកងខាងណាខ្ញុំមិនដឹងដែរ តែកងពលតាសារឿនហ្នឹងគេហៅកងពល៨០១ ខាងតាសាននេះកងពល៩២០ ។

វណ្ណៈ:	ចឹងកាលមីងនៅភ្នំពេញម្តុំទួលគោកហ្នឹង មីងមានដើរចល័តនៅណាទៅដល់មុខវាំងអីទេ?

រី:	គេទៅមុខវាំងខ្ញុំមិនបានទៅផង អត់បានដើរទៅ ព្រោះអីខ្ញុំឈឺគេឲ្យនៅកន្លែងអត់មានបានដើរឆ្ងាយហ្នឹងគេ ចឹងបានថា អត់បានឃើញព្រហ្មមុខបួនគេ មុខភ្នំពេញអត់បានឃើញ ។

វណ្ណៈ:	ចឹងមីងនៅទួលគោកហ្នឹងរយៈពេលប៉ុន្មានខែបានគេបញ្ជូនមីងនៅដល់មណ្ឌលគិរីទៀត?

រី:	នៅប៉ុន្មានខែទេ នៅមិនបានកន្លះឆ្នាំទេ ។

វណ្ណៈ:	ចឹងឆ្នាំ១៩៧៥ហ្នឹងដដែលគេបញ្ជូនទៅ?

រី:	ចាស!ឆ្នាំ៧៥ហ្នឹងដដែល ខ្ញុំចុះទៅមណ្ឌលគិរី បានប្រហែលកន្លះឆ្នាំដឹង ។

វណ្ណៈ:	ចឹងពេលវាយបែកភ្នំពេញហើយមីងមានបានទៅលេងផ្ទះអីទេ?

រី:	អត់ទេ ខាងកងគេប្រាប់ថា ទៅតាមខេត្តដល់ពេលទៅទួលខ្លះទៅលេងផ្ទះ គេថាកើតសង្គ្រាមអីទៀត អីបាក់ទ័ពអីមកពីខាងរតនគិរីមណ្ឌលគិរីអី ខ្ញុំនៅក្របេះព្រុគេនិយាយថា វាយគ្នាទៀតក៏បែកបាក់គ្នាត្រឹមក្របេះហ្នឹងមក ។

វណ្ណៈ:	បាទ ។

រី:	គេផ្លាស់កន្លែងមកឆ្នាំ៧៥ - ៧៦ គេផ្លាស់កន្លែងមកដល់កោះញែក មកនៅកោះញែកហ្នឹងកាលនៅត្រឹមក្របេះគេឲ្យធ្វើពេទ្យទៀត មកនៅធ្វើពេទ្យបានមួយរយៈដែរ ដល់ផ្លាស់កន្លែងទៅនៅកោះញែក ចេញពីហ្នឹងទៅទាហានបាក់ទ័ពមកពីខាងរតនគិរីនោះ ក៏បែកបាក់គ្នាវាយតាំងពីត្រឹមហ្នឹងមកក៏រត់ចូលព្រៃរហូត ។

វណ្ណៈ:	ចឹងមីងបានចេញពីឆ្នាំ១៩៧៥ទៅខេត្តមណ្ឌលគិរី?

រី:	ចាស ។

វណ្ណៈ:	ចឹងនៅកងពល៩២០ដដែល?

រី:	ចាស ។

វណ្ណៈ:	ពេលមីងទៅហ្នឹង មីងជិះអីទៅ?

រី:	កាលចេញពីភ្នំពេញជិះឡានមក ។

វណ្ណៈ:	ជិះឡានដល់ណា?

វី: ឡានច្រើនណាស់កាលហ្នឹង ចុះត្រឹមព្រែកញ្ជៀបបានជិះកាណូតមកចូលដៃក្រចេះ ឡើងត្រឹមក្រចេះហ្នឹងតែម្តង ។

វណ្ណៈ: មានគ្នាប្រហែលជាប៉ុន្មាននាក់ដែរ?

វី: មិនដឹងជាប៉ុន្មានពាន់នាក់ទេ មានឡានច្រើន ។

វណ្ណៈ: ចឹងមួយកងពលហ្នឹងតែម្តង?

វី: ចាស!មួយកងពល ទាំងស្រីទាំងប្រុស ។

វណ្ណៈ: ចឹងកាលហ្នឹងមកឈប់ត្រឹមក្រចេះ?

វី: ចាស!មកស្នាក់នៅត្រឹមក្រចេះ តែមិនដឹងខែ ខែប៉ុន្មានទេ មកនៅក្រចេះហ្នឹង ។

វណ្ណៈ: មកនៅត្រឹមក្រចេះហ្នឹងរយៈពេលប៉ុន្មានដែរ បានបញ្ជូនទៅទៀត?

វី: ដឹងថានៅបានប៉ុន្មានខែទេ ដឹងថាឆ្នាំ៧៦ហ្នឹងឯង ផ្លាស់កន្លែងមកនៅកោះញែក ។

វណ្ណៈ: ចឹងអត់មានឈប់នៅខេត្តមណ្ឌលគិរីសិនទេ?

វី: ចាស!អត់មានឈប់នៅមណ្ឌលគិរី ។

វណ្ណៈ: ចឹងកាលហ្នឹងអត់មានទៅដល់ក្រចេះសម្រាកពីរបីថ្ងៃបញ្ជូនទៅទៀតទេ សម្រាកនៅហ្នឹងយូរដែរ?

វី: នៅយូរដែលតែកងនារីគេទៅ ទៅរតនគិរីមណ្ឌលគិរីអីគេទៅតាមកង តែខ្ញុំនៅកន្លែងពេទ្យហ្នឹងនៅត្រឹមក្រចេះសិន ។

វណ្ណៈ: ចឹងពេលទៅដល់ខេត្តក្រចេះភ្លាម មានអ្នកទៅខ្លះមានអ្នកនៅខ្លះ?

វី: អ្នកនៅមន្ទីរពេទ្យនៅក្នុងមន្ទីរពេទ្យ គេចាត់តាំងឲ្យនៅតាមកងទៅ ។

វណ្ណៈ: ចឹងកងពល៩២០ហ្នឹងចេញទៅខេត្តមណ្ឌលគិរីភ្លាមៗដែលទេ?

វី: ភ្លាមៗដែរ ។

វណ្ណៈ: តែគេទុកមួយចំនួននៅក្រចេះសិន?

វី: នៅក្រចេះហ្នឹង នៅតែអ្នកចេះពេទ្យទេ ។

វណ្ណៈ: ចឹងមីងធ្វើពេទ្យ?

វី: ខ្ញុំគេរើសឲ្យទៅនៅពេទ្យវិញណាស់ ទៅនៅរតនគិរីមណ្ឌលគិរី កោះមីយើល នៅតាមកង ។

វណ្ណៈ: ចឹងនៅក្នុងពេទ្យ៩២០ហ្នឹងដែរ?

វី: ចាស!ទៅនៅពេទ្យហ្នឹងវិញដដែល ។

វណ្ណៈ: ចឹងឆ្នាំ១៩៧៦ ចេញទៅមណ្ឌលគិរីហ្នឹង គេយកឡានមកយកបុយ៉ាងម៉េច?

រី:	មានឡានដែរ ឡានគេដឹកដល់កោះញែក ដឹកទៅទាំងអ្នកជំងឺដឹកទាំងពេទ្យ ទាំងពេទ្យនិងអ្នកជំងឺដែលនៅក្រចេះ ដឹកទៅទាំងអស់ ទៅដល់ផ្ញើកន្លែងឲ្យអ្នកជំងឺនៅ ។

វណ្ណៈ:	ចឹងកាលមីងនៅដល់កោះញែក ខេត្តមណ្ឌលគិរីហ្នឹងគេឲ្យមីងធ្វើអីដែរ?

រី:	ខ្ញុំនៅពេទ្យរហូត ។

វណ្ណៈ:	ចឹងមីងធ្វើពេទ្យ?

រី:	ចាស! ពេទ្យព្យាបាលអ្នកជំងឺរហូត ។

វណ្ណៈ:	ចឹងពេទ្យនៅមណ្ឌលគិរីហ្នឹងមានគ្នាប៉ុន្មាននាក់?

រី:	ពេទ្យទាំងប្រុសទាំងស្រី មានប៉ុន្មានទេ ប្រហែល៣០នាក់ដឹង ។

វណ្ណៈ:	មានតិច?

រី:	មិនដឹងជា៣០ដឹងប៉ុន្មានដែរ មានច្រើនដែរ ។

វណ្ណៈ:	ប្រធានពេទ្យពីណា?

រី:	ប្រធានពេទ្យឈ្មោះ ដា ។

វណ្ណៈ:	ស្រីប្រុស?

រី:	ស្រីឈ្មោះ ដា ប្រុសឈ្មោះ តាដូ និងតាសើ មកពីខាង៨០១ ពេទ្យនៅហ្នឹង ។

វណ្ណៈ:	ចឹងឈ្មោះ តាដូ តាសើ?

រី:	ចាស ។

វណ្ណៈ:	តែនៅហ្នឹងជាពេទ្យរបស់កងពល៩២០?

រី:	ចាស ។

វណ្ណៈ:	ចឹងកាលហ្នឹងពេទ្យកងពល៩២០ហ្នឹង កាលមីងនៅហ្នឹងជំងឺភាគច្រើន ជាជំងឺអីគេ ជាជំងឺគ្រុនចាញ់ឬមួយយ៉ាងម៉េច?

រី:	ភាគច្រើនគ្រុនចាញ់ រតនគិរី បញ្ជូនពីហ្នឹងមកវិញ ភាគច្រើនចាញ់សន្លំបាត់មាត់ ខ្លះសន្លំដំបៅគូទអស់ ។

វណ្ណៈ:	ចឹងមានស្លាប់ច្រើនទេ?

រី:	ស្លាប់ច្រើន ខ្លះដឹកមកមិនដឹងខ្លួនផង មកពីខាងរតនគិរីមណ្ឌលគិរីមកពីខាងកោះមីយើលចាញ់ណាស់ខាងហ្នឹង ដឹកមកឡានៗ ។

វណ្ណៈ:	ដឹកទាំងឡាន?

រី:	ចាស ។

វណ្ណៈ:	ភាគច្រើនជាយោធា?

រី៖ យោធា សុទ្ធតែយោធាដែលបញ្ជូនទៅណាស់ នៅតាមកង ។

វណ្ណៈ៖ ចឹងមានប្រជាជនទៅព្យាបាលហ្នឹងទេ?

រី៖ ប្រជាជនអត់ទេ សុទ្ធតែកងទ័ពទាំងអស់ ទាំងស្រីទាំងប្រុស ។

វណ្ណៈ៖ ចឹងមានន័យថាស្លាប់ច្រើន?

រី៖ ស្លាប់ច្រើននៅខាងហ្នឹង វាចាញ់ពេក ។

វណ្ណៈ៖ ដល់ពេលស្លាប់ហ្នឹងគេដុតចោលឬមួយកប់?

រី៖ កប់ហ្នឹង យកទៅកប់មានកន្លែងគេឡានពេទ្យគេដឹកទៅកប់ តាំងពីមេធំក៏មានដែរ ប្រធានវរសេនាធំអីក៏មាន តាមកង កងតូច កងធំ មានស្លាប់ខ្លះ ។

វណ្ណៈ៖ ចឹងតាសាន មានបានទៅលេងពេទ្យហ្នឹងទេ?

រី៖ គាត់មិនដែលទៅទេ នៅតែតាមកង ។

វណ្ណៈ៖ ចឹងមីងកាលហ្នឹងអត់មានដែលទៅសមរភូមិមុខទេ មីងនៅតែខាងក្រោយ ខាងនៅមណ្ឌលគិរីហ្នឹង?

រី៖ កាលនៅមណ្ឌលគិរីខ្ញុំមិនដែលបានទៅទេ ខ្ញុំនៅតែកន្លែងពេទ្យអីក្រោយ ។

វណ្ណៈ៖ ចឹងក្រោយមកទៀត នៅក្នុងមន្ទីរពេទ្យហ្នឹងមានការចាប់ខ្លួនប្រធានមន្ទីរពេទ្យនៅហ្នឹងដែលទេកាលហ្នឹង?

រី៖ មាន មានចាប់ខ្លួនដែរ គេថាបញ្ជូនឲ្យទៅរៀនអីចឹងទៅ តែបាត់រហូតទៅ ។

វណ្ណៈ៖ ចឹងមេណាដែលគេចាប់?

រី៖ មេឈ្មោះអីទេ មេ តាសើ អីមិនដឹង ។

វណ្ណៈ៖ ចឹងតាសើហ្នឹងគេចាប់គាត់ដែរ?

រី៖ ទេ ។

វណ្ណៈ៖ ពេទ្យមិនមានឈ្មោះ មិញហ្នឹង ឈ្មោះ ដា ឈ្មោះ ជូ ឈ្មោះ សើ ចឹងបីនាក់ហ្នឹងគេចាប់ដែលឬមួយអត់ទេ?

រី៖ ទេ កាលហ្នឹង ។

វណ្ណៈ៖ ឬមួយគេចាប់ហើយបានគេយកពួកហ្នឹងមកដាក់?

រី៖ ខ្ញុំមិនដឹងថា យ៉ាងម៉េចទេ ដឹងថាគេឲ្យទៅរៀនអីទៅ ។

វណ្ណៈ៖ ចឹងទៅរៀនបាត់?

រី៖ ទៅរៀនបាត់ទៅ ក្រោយមកបានគេបញ្ជូនប្រពន្ធកូនទៅតាមក្រោយ ។

វណ្ណៈ៖ ចឹងប្រពន្ធកូនគេបញ្ជូនទៅបាត់ទៀត?

រី៖ ចាស១!ប្រពន្ធកូនគេបញ្ជូនទៅក្រោយទៅនៅមួយកន្លែង យកទៅដាក់មួយកន្លែង។
វណ្ណៈ៖ ចឹងនៅហ្នឹងគណៈភូមិភាគអីមីងមានស្គាល់ទេ?
រី៖ អត់ទេ ខ្ញុំអត់ស្គាល់ទេ។
វណ្ណៈ៖ គណៈតំបន់អី?
រី៖ អត់ស្គាល់ផង គ្រាន់តែឮគ្រាន់តែដឹង យើងគ្រាន់តែឮយើងមិនទាន់បានឃើញ។
វណ្ណៈ៖ ចឹងឮឈ្មោះអីគេដែរ?
រី៖ ឮគណៈភូមិភាគអីខ្ញុំមិនសូវដឹងទេ។
វណ្ណៈ៖ ចឹងកាលហ្នឹង មីងអន់អីដែរ អត់មានគ្រោះថ្នាក់ដោយសារគេចាប់ដែរ?
រី៖ ខ្ញុំអត់មានខ្សែស្រឡាយអីទេ។
វណ្ណៈ៖ មីងកូនចៅគេដែរ?
រី៖ ចាស។
វណ្ណៈ៖ ចឹងបុគ្គលិកពេទ្យនៅហ្នឹងមានបាត់ខ្លួនខ្លះទេ?
រី៖ ទេ ដូចជាមិនអីទេ។
វណ្ណៈ៖ ចឹងក្រោយមកទៀត ការព្យាបាលជំងឺគ្រុនចាញ់ហ្នឹងមានប្រសិទ្ធភាពទេ មានថ្នាំសង្កូវមកពីខាងណាវិញ?
រី៖ កាលហ្នឹងថ្នាំសង្កូវមកពីខាងហ្នឹង មិនដឹងជាមកពីខាងណាទេ ដូចថាមិនសូវដឹងដែរ គ្រាន់មានតែថ្នាំមកព្យាបាល ចេះតែព្យាបាលទៅខ្ញុំមិនសូវដឹងដែរ យើងខាងក្រោយគេដែរ។
វណ្ណៈ៖ ចឹងមីងចេះចាក់ថ្នាំ ចេះព្យួរសេរ៉ូអីទេ?
រី៖ ចេះខ្លះដែរ។
វណ្ណៈ៖ ចឹងនិយាយទៅ មីងចូលសមរភូមិតិចជាងធ្វើការនៅមន្ទីរទេ ធ្វើពេទ្យបានយូរជាង?
រី៖ ចាស។
វណ្ណៈ៖ ចឹងពីឆ្នាំ១៩៧៥ទៅ មីងបានធ្វើពេទ្យរហូតដល់វៀតណាមចូលតែម្តង?
រី៖ ចាស!គិតទៅវាក្រលិកក្រលាក់ច្រើនណាស់ ខ្ញុំនិយាយទៅចូល៧៣ហ្នឹងមក។
វណ្ណៈ៖ ចឹងយើងនិយាយពីឆ្នាំ១៩៧៥ដល់៧៩វិញ កាលមីងនៅមណ្ឌលគិរី?
រី៖ ចាស!ខ្ញុំនៅពេទ្យបានយូរដែរ ដល់៧៩បានខ្ញុំឈប់ ៧៩ពេលយើងរំដោះឃួនមកម្តងទៀតហ្នឹងឯង វាយគ្នាម្តងទៀតបានខ្ញុំឈប់ពីពេទ្យ។
វណ្ណៈ៖ ចឹងកាលវៀតណាមចូលដល់នៅឆ្នាំ១៩៧៩ហ្នឹង មីងរត់ទៅតាមអង្គភាពឬមួយមីងមានចិត្តរត់មករកស្រុកកំណើតដែលកាលហ្នឹង?

រី៖	អត់ទេ នឹកឃើញតែខ្លាច ក្រោយមកឮពាក្យចាមអារាមថា ចូលទៅនៅភូមិអី អ្នកសារភាពអី យួនអាករបេះតែខ្លាចអត់ហ៊ានទៅទេ គេថារហូតបងប្អូនខ្ញុំ មិញកាលពីដាច់ភ្នំពេញ៧៥បង ឯងម៉េចមិនទៅផ្ទះ មកស្រួលបួលគេផ្តាច់ខ្លួនហើយក៏មិនហ៊ានទៅបេះតែខ្លាច ។

វណ្ណៈ	ចឹងពេលឆ្នាំ៧៩ហ្នឹង កងពល៩២០របស់មីងហ្នឹង មានរត់ទៅណាទៀតប្តុនៅហ្នឹងប្តុរត់ទៅខាង ម៉ៅឡៃ ខាងជាយដែនអីណាណីទៀត មីងអាចរៀបរាប់បានទេ ៧៩វៀតណាមចូលហើយ ពេលវៀតណាមចូលហើយខាងខ្មែរក្រហមចាញ់?

រី៖	ចាស ។

វណ្ណៈ	ចឹងពេលហ្នឹងកងពល៩២០ហ្នឹងរត់ទៅខាងណាខ្លះ?

រី៖	រត់ទៅនៅគ្រប់កន្លែងខ្ញុំមិនសូវដឹងដែរ គ្រាន់ដឹងថារត់ពីហ្នឹងទៅ ទៅនៅតាមព្រៃ មិនដឹងថានៅ ដល់ណាទេ ។

វណ្ណៈ	ចឹងមានរត់ដល់ដីថៃទេ?

រី៖	អត់ទេ ចូលដល់ដីថៃឆ្នាំប៉ុន្មានទេ ខ្ញុំមកនៅដីថៃនេះឆ្នាំ១៩៨៤ហើយ ៨៤បានមកនៅដីថៃ រត់ពីហ្នឹងមកទៅនៅព្រៃអីណាអីណីទេ ឆ្ងាយណាស់ បានមកឡើងភ្នំវិញ ឡើងភ្នំឆ្នាំប៉ុន្មានទេ ។

វណ្ណៈ	ចឹងដោយសារមីងមិនចាំកន្លែង ចឹងខ្ញុំនិយាយចំណុចៗឲ្យកាលឆ្នាំ៧៩ហ្នឹង?

រី៖	ចាស ។

វណ្ណៈ	ព្រោះ៧៩ហ្នឹង មានអ្នកខ្លះរត់ទៅនៅ៨០៨ខ្លះទៅ៨០១អត់ទេ ខ្លះទៅ១០០១-១០០២ និង១០០៣?

រី៖	ចាស!ខ្ញុំទៅនៅ១០០១ហ្នឹងឯង ។

វណ្ណៈ	ចឹង?

រី៖	ចាស ។

វណ្ណៈ	ចឹងមីងរត់ចេញពីមណ្ឌលគិរីតាមអន្លុកាពកាត់ព្រៃហ្នឹង មកនៅ១០០១?

រី៖	ចាស!នៅ១០០១ ។

វណ្ណៈ	ចឹង១០០១ហ្នឹង ពីណាគ្រប់គ្រង?

រី៖	១០០១នៅកងខ្ញុំ ។

វណ្ណៈ	បាទ ។

រី៖	ខ្ញុំទៅនៅកងនារី មានឈ្មោះតាស៊ីទេ ភ្លេចឈ្មោះ ។

វណ្ណៈ	ចឹងគេថានៅ១០០១ហ្នឹងតាសុន សេន មែនដែលទេ?

រី៖	ចាសៗ!តាហ្នឹង ឈ្មោះ តាហ្នឹង ។

វណ្ណៈ	ចឹងតាសុន សេន?

រីៈ	ចាស ។

វណ្ណៈ	តែគាត់គ្រប់គ្រងពីលើ តែមីងនៅក្នុងកងពល៩២០តាសាន ដដែល?

រីៈ	ចាស ។

វណ្ណៈ	ចឹងកាលមីងរត់ពេលហ្នឹង មានបានទៅជួបតាសាន នៅ១០០១ហ្នឹងដែលអត់?

រីៈ	ទេ ទៅនៅចេញពីកងពល៩២០មក មកនៅ១០០១ហ្នឹង នៅកងពល៩២០ដដែលទេដឹង ។

វណ្ណៈ	ចឹងបើតាសាន កងពល៩២០ដដែលហើយ?

រីៈ	ចាស! នៅកងដដែលទាល់មកខ្ញុំនេះ ទាល់តែឡើងភ្នំដងរែកនេះហើយ តើបានជួបកងតាសា រឿន តា៨០១ ចូលកងរាល់ថ្ងៃនេះ កាលពីនោះមកនៅពួកដដែលហ្នឹង ទាល់តែមកក្រោយ កើតវិញ យើងឆ្លងទន្លេមកឡើងភ្នំដងរែកនេះ នៅក្នុងព្រៃត្រាត់ត្រែងណាស់ មិនដឹងណាណី ទេ ខ្ញុំមិនសូវស្គាល់ផង មិនស្គាល់កន្លែងតំបន់ឃុំស្រុកគេ ។

វណ្ណៈ	ចឹង១០០១ហ្នឹងនៅម្តុំណា មីងមានដឹងទេ នៅប្រកអីគេម្តុំណាហ្នឹង?

រីៈ	នៅហ្នឹងប្រក១០០១ហ្នឹង គេហៅសមរភូមិគេហ្នឹង មានវាលចៀស មានត្រពាំងគល់ មានអី ខ្លះទេ បើប្រធានភូមិនោះបានគាត់ស្គាល់ច្រើន ខ្ញុំមិនសូវស្គាល់អស់សមរភូមិ ។

វណ្ណៈ	ចឹងកាលមីងទៅដល់១០០១ហ្នឹងនៅឆ្នាំ៧៩ដដែល?

រីៈ	អត់ទេ ខ្ញុំបានឡើងភ្នំដងរែកហ្នឹងឆ្នាំ១៩៨០នៅក្នុងព្រៃយូរ រត់ពី៧៩ហ្នឹងទៅរត់ត្រាត់ត្រែង នៅក្នុងព្រៃ ហូបក្តួចអីហ្នឹងយូរ ដល់ឆ្នាំ៨០បានខ្ញុំឡើងភ្នំ ។

វណ្ណៈ	ឡើងភ្នំប្រក១០០១ហ្នឹង?

រីៈ	ចាស! ឆ្នាំ៨០ហ្នឹងបានឡើងភ្នំមកនៅ១០០១ហ្នឹង រឿងខែថ្ងៃអីមិនសូវបានចាំ ។

វណ្ណៈ	ចឹងមកនៅ១០០១ឆ្នាំ១៩៨០?

រីៈ	ចាស ។

វណ្ណៈ	ចឹងពេលមកនៅ១០០១ហ្នឹងមានស្គាល់មេដឹកនាំខ្មែរក្រហមណាខ្លះទេ?

រីៈ	នៅ១០០១មេខ្មែរក្រហមឈ្មោះ តាអីទេ ។

វណ្ណៈ	ចឹងនៅ១០០១មានបានជួបតាម៉ុក អីឬនៅ?

រីៈ	១០០១ហ្នឹងនៅទេដឹង ។

វណ្ណៈ	នៅទេ?

រីៈ	នៅទេ មិនទាន់បានស្គាល់ទេ នៅតែ៩២០ដដែលហ្នឹង ។

វណ្ណៈ	ចឹងនៅ១០០១ កងពល៩២០ហ្នឹង មីងនៅដឹកជញ្ជូនប្អូយនៅខាងអី?

រី:	នៅតាមកង កាលហ្នឹងអត់មានធ្វើអីទេ ចេញពីពេទ្យអីអស់ហើយគ្មាន ឈប់ធ្វើពេទ្យអីហើយ បែកបាក់អ្នកជំងឺអស់ទៅ ។

វណ្ណៈ:	តែកាលហ្នឹងកម្លាំងខ្មែរក្រហមបានប្រមូលផ្តុំគ្នាឡើងវិញ ដើម្បីវាយបកជាមួយទាហានវៀតណាមនិងកម្លាំងខាងរដ្ឋាភិបាល?

រី:	ចាស ។

វណ្ណៈ:	ចឹងខាងនារីខ្មែរក្រហមភាគច្រើនខ្ញុំដឹងថា នារីចូលផ្នែកដឹកជញ្ជូន បើប្រុសៗខាងសមរភូមិមុខចូលទៅវាយផ្ទាល់ៗឬទៅឃោសនា?

រី:	ចាស!ខ្ញុំចេញពី៧៩ហ្នឹងទៅ នៅតាមព្រៃត្រាត់ត្រែងរហូតមកនៅ១០០១ហ្នឹង គ្មានធ្វើអីទៀតទេ ខ្ញុំនៅតាមកងគេតែម្តងអត់មានធ្វើអីទេ ។

វណ្ណៈ:	ចឹងអត់មានធ្វើអីទេ នៅទំនេរ?

រី:	ចាស!អត់មានធ្វើអីទេ ។

វណ្ណៈ:	កងប៉ុន្មាន អង្គភាពលេខប៉ុន្មាន?

រី:	នៅក្នុងកងនារីហ្នឹង ដល់ខ្ញុំឡើងទៅនៅលើភ្នំនោះ គេហៅឃ្លាំងក្រោយកងដឹកជញ្ជូនគ្រាប់ជញ្ជូនគ្រាប់ទុកដាក់ ។

វណ្ណៈ:	ចឹងឆ្នាំណា មីងមកនៅ៨០១វិញ ចេញពីតាសាន មានហេតុអីបានចាកចេញពីតាសាន?

រី:	គេចាត់តាំងកង គេបំបែកគ្នា នៅកងបំបែកគ្នាកាលហ្នឹង មកនៅបែកគ្នាហ្នឹង ខ្ញុំមកនៅកងដឹកជញ្ជូន កងដឹកជញ្ជូនគ្រាប់អីលាក់ទុកដាក់ ។

វណ្ណៈ:	ចឹងមកនៅ៨០១ជាមួយតាសារឿន វិញនៅឆ្នាំ៨០ប៉ុន្មាន ចឹងនៅ១០០១ហ្នឹងនៅមួយឆ្នាំឬមួយពីរឆ្នាំ?

រី:	ខ្ញុំនៅយូរដែរ ។

វណ្ណៈ:	ចឹងមីងមានគ្រួសារឆ្នាំណាចឹង?

រី:	ខ្ញុំមានគ្រួសារឆ្នាំ១៩៨០ហ្នឹងអះ!ឆ្នាំ៨២ខ្ញុំ ។

វណ្ណៈ:	ចឹងឆ្នាំ៨២ មីងការនៅណា ការនៅ១០០១ឬការនៅលើភ្នំ រៀបការនៅណា?

រី:	ការនៅ១០០១ហ្នឹងតែប្តីខ្ញុំស្លាប់ ស្លាប់នៅ១០០១ហ្នឹង ស្លាប់នៅសមរភូមិ ។

វណ្ណៈ:	ប្តីដែលស្លាប់ហ្នឹងឈ្មោះអីដែរ?

រី:	ឈ្មោះ ភក្តិ កាលហ្នឹងគេហៅកងគេ៨២ ។

វណ្ណៈ:	ចឹងគ្រួសារក្រោយ មីងការនៅឆ្នាំណា?

រី:	ខ្ញុំការនៅដីថៃនេះឯង ខ្ញុំរៀបការឆ្នាំ៨៤ហ្នឹង ។

វណ្ណៈ	ចឹងឆ្នាំ១៩៨៤ មីងរៀបការនៅដីថៃ?

រី:	ចាស!មកដីថៃវត់ពី១០០១មកទៀតហើយហ្នឹង មកនៅដីថៃ ។

វណ្ណៈ	នៅដីថៃយ៉ាងម៉េចបានរត់មកនៅដីថៃវិញ ក្រែងយើងចលនាជញ្ជូនគ្រាប់មកសមរភូមិ?

រី:	កាលហ្នឹងខ្ញុំមានគ្រួសារហើយមកនៅតាមកង មកនៅខាងកងខាងគ្រួសារ ដូចថាប្ដីៗកងទ័ពអីចឹងនៅមួយកន្លែងចឹង ។

វណ្ណៈ	ចឹងមីងចូលកងដឹកជញ្ជូនហ្នឹងបានតែរយៈពេលខ្លីទេ?

រី:	ចាស ។

វណ្ណៈ	ព្រោះអីឆ្នាំ៨០-៨១បានមួយឆ្នាំ៨២ មីងរៀបការ ការហើយលែងទៅសមរភូមិហើយមែនទេ?

រី:	ចាស ។

វណ្ណៈ	ចឹងពេលជញ្ជូនចុះមកដល់ម្ដងៗ មីងចុះមកដល់ណាទៅ ហើយកាលហ្នឹងមានគ្រោះថ្នាក់ខ្លះដែរពេលហ្នឹង?

រី:	កងគេមាន កងខ្ញុំមិនដែលទេ កងខ្ញុំជញ្ជូនទៅជិតៗនៅត្រឹម១០០១ ជញ្ជូនទៅដាក់ត្រឹមវាលចៀសអីដល់មកនៅទឹកចេញអី មិនដែលជញ្ជូនទៅសមរភូមិឆ្ងាយទេ ដូចកាលនៅវាយសង្គ្រាមទេ កាលហ្នឹងបានជញ្ជូនទៅសមរភូមិឆ្ងាយៗ ។

វណ្ណៈ	បាទ ។

រី:	ដល់យើងមកឡើងភ្នំដងរែកនេះហើយ ខ្ញុំមានប្ដីមានអីក៏នៅតាមកងវរហូត ។

វណ្ណៈ	ចឹងមីងនៅដីថៃរយៈពេលប៉ុន្មាន បានមីងមករស់នៅលើភ្នំដងរែកនេះ?

រី:	នៅដីថៃវាអត់កំណត់ ព្រោះនៅមួយកន្លែងចឹងទៅ ចំនួនមួយខែពីរចឹងសភាពការណ៍អត់ស្រួលផ្លាស់កន្លែងទៅទៀតទៅ លើកកញ្ជើរដើរនៅត្រង់នោះទៀតទៅ សភាពការណ៍មិនស្រួលផ្លាស់ទៅត្រង់នោះទៀតទៅ វាអត់មានកំណត់ ។

វណ្ណៈ	ចឹងកាលហ្នឹង យ៉ាងម៉េចបានជាមីងមិនរត់ទៅរស់នៅជំរំ ដើម្បីបានចេញទៅស្រុកក្រៅអីយ៉ាងបានជាមីងមិនចេញទៅ?

រី:	ខ្ញុំអត់ទៅ ដូចថាចិត្តគ្មានទឹកឃើញថា ទៅណាឆ្ងាយទៅមិនរួច មិនដឹងថាទៅណាដឹងថានៅក្នុងជួរគេ ។

វណ្ណៈ	កុំអីមីងបានទៅដល់អាមេរិកឬអូស្ត្រាលីហ្នឹងគេ?

រី:	ចាស!គ្មានចិត្តទឹកឃើញបែកបាក់ពីកងពីអីក៏នៅរហូតទៅ ។

វណ្ណៈ	មីងស្នេហាជាតិ?

រីៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងបើគិតឃើញដូចឥឡូវទៅបាត់ហើយ?

រីៈ ចាស!អត់ចេះគិតនៅតែក្នុងដួរហួតទៅ ។

វណ្ណៈ ចឹងមីងការហើយមានកូនជាបន្តបន្ទាប់មក?

រីៈ ខ្ញុំនៅ១០០១ហ្នឹងប្ដីខ្ញុំដែលថាស្លាប់នោះបានកូនមួយយកគ្នាបានពីរឆ្នាំ ។

វណ្ណៈ ស្លាប់ទៅ?

រីៈ ចាស!ស្លាប់នៅសមរភូមិ ដល់ពេលប្ដីខ្ញុំយកក្រោយនេះ ការក្រោយនៅដីថៃ៨៤ហ្នឹង មានកូនប្ដីទៅសមរភូមិបាត់ទៅក៏នៅថៃតែកូន កាលហ្នឹងកូនខ្ញុំទើបមួយទើបពីរហ្នឹងនៅ១០០១ មានកូនមួយហ្នឹង ដល់មកនៅដីថៃនេះខ្ញុំមានកូនមួយរត់ព្រោះអីប្ដីធ្វើការនៅកំពង់ធំ ឆ្ងាយជួនកាលមួយឆ្នាំជាងអីបានមកម្ដង ។

វណ្ណៈ ចឹងមីងមានអារម្មណ៍តូចចិត្តទេ យើងមានប្ដីហើយមិនបាននៅជុំគ្នាប្ដីទៅសមរភូមិ ចឹងរាល់ថ្ងៃមានបន់ស្រុនយ៉ាងម៉េច?

រីៈ ខ្លាចហើយមិនដឹងធ្វើយ៉ាងម៉េច បើប្រទេសជាតិចឹងហើយ យើងចេះតែទ្រាំចឹងទៅ ចេះថៃកូនថៃចៅចឹងទៅ ។

វណ្ណៈ ចឹងគេឲ្យនៅក្រោយគេឲ្យនៅបិតចំរូងអីដែរ ដូចថាយើងទៅមុខមិនរួច?

រីៈ បិតតើ កាលនៅ១០០១បិតចំរូង ។

វណ្ណៈ គេបិតយ៉ាងម៉េចចំរូងហ្នឹង?

រីៈ ចំរូងគេបិតស្រួចៗមានគន្លាក់ ។

វណ្ណៈ ហើយមានប្រវែងប៉ុន្មាន ប៉ុន្មានគីកទៅ?

រីៈ ប្រវែងនេះ ។

វណ្ណៈ ចឹងប្រហែលជាបីបួនគីកដែរ?

រីៈ ចាស ។

វណ្ណៈ គេយកអីធ្វើ?

រីៈ ឫស្សី ។

វណ្ណៈ ចឹងក្រៅពីបិតចំរូង មានគ្រាប់រំសេវជំនួយពីប្រទេសណាដែរ?

រីៈ ចាក់ចំរូងឫស្សីហ្នឹងចោលតែម្ដង អត់មានគ្រាប់អីទេ ។

វណ្ណៈ កាលហ្នឹងគេប្រើចំរូងផង និងមានគ្រាប់មកទៀតនោះ?

រីៈ ខ្ញុំមិនដឹងថា ជំនួយមកពីខាងណាទេ ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ	ចឹងចំរូងហ្នឹងមានប្រសិទ្ធភាពទេ ពេលយកទៅដាក់?

រីៈ	មានដែលគេ យកទៅចាក់ចោលតាមផ្លូវ វាយគ្នាអីដាក់ ដូចថាតាមដេញយើងអីយើងចាក់ស្អាត់ផ្លូវស្អាត់អី ។

វណ្ណៈ	ចឹងពេលរត់មកដាន់?

រីៈ	ចាស!រត់មកដាន់ទៅ ។

វណ្ណៈ	ចឹងកាលហ្នឹងគេមិនសូវប្រើមីនទេ ដំបូងៗឬមួយយ៉ាងម៉េច?

រីៈ	កងទ័ពមានប្រើខ្លះដែលដូចថា យើងរត់ចំរូងយើងចាក់ស្អាត់មុខចឹង ចាក់កាត់ខាងនោះចឹងទៅដូចថាមកហួសចំរូងចឹងទៅមានគេដាក់មីនអីដែរ កងទ័ពមិនដឹងគេដាក់របៀបណាខ្ញុំមិនសូវបានទៅមុខដែរ នៅតែសមរភូមិក្រោយ ។

វណ្ណៈ	ចឹងយើងគ្រាន់អ្នកបិតទេ?

រីៈ	ចាស!យើងគ្រាន់តែបិតគេយកទៅចាក់ ។

វណ្ណៈ	ចឹងឆ្នាំណាដែលមីងបានជួបតាម៉ុក គាត់ជួយខបត្តម្ភស្គាល់តាម៉ុក អី?

រីៈ	ហ្នឹងមក ។

វណ្ណៈ	មកនៅណាហើយ?

រីៈ	មកនៅនេះចេញពីនេះ នៅនេះឆ្នាំ១៩៩៣ មកនៅភូមិទួលប្រាសាទនេះ ។

វណ្ណៈ	ចឹងមកនៅភូមិទួលប្រាសាទឆ្នាំ៩៣ហើយ?

រីៈ	ចាស!៩៣ មួយសារពេលមានសភាពមិនស្រួលរត់ទៅនៅអូរស្វាយនោះ ។

វណ្ណៈ	ចឹងមីងមានដឹងថា តាម៉ុក ផ្ទើផ្លូវចុះមកពីអន្លង់វែងហ្នឹងនៅឆ្នាំណា ផ្ទើផ្លូវមករហូតហ្នឹង?

រីៈ	ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ	ចឹងមិនសូវដឹងទេ?

រីៈ	ចាស ។

វណ្ណៈ	ចឹងតាម៉ុក កាប់ឈើអីមានដឹងទេ លក់ឲ្យថៃដើម្បីយកលុយដោះស្រាយដឹងទេ?

រីៈ	ខ្ញុំអត់ដឹងដែលដឹងថា ជួបគាត់ត្រឹមខ្ញុំនៅអូរស្វាយហ្នឹង មកចាត់តាំងប្រឡូកកងទ័ពគ្នា កងទ័ពចំរុះគ្នា បានដឹងថាខ្ញុំចូលនៅនេះ ចូលកង៨០ ១រហូតមក ។

វណ្ណៈ	ចឹងតាសារឿន?

រីៈ	ចាស ។

វណ្ណៈ	ចឹងតាសារឿន ប្រធានកងពលរបស់មីងហ្នឹង មើលទៅអត្តចរិករបស់គាត់យ៉ាងម៉េចដែរ?

រី:	ទេ ខ្ញុំមិនដែលបានជួបផ្ទាល់ដែរ អត្តចរិករបស់គាត់ដឹងថាយ៉ាងម៉េច ស្គូតបូតដែលដឹងខ្ញុំមិនសូវបានចុះដាប់ជាមួយដែរ ព្រោះអីនៅតែមុនអីនោះ ។

វណ្ណៈ:	ចុះតាម៉ុក វិញ?

រី:	តាម៉ុក គ៏ឮតែឈ្មោះ ខ្ញុំមិនដែលបានឃើញដែរ ។

វណ្ណៈ:	ចឹងមិនដែលជួបទេ?

រី:	ចាស!ទាល់តែសព្វថ្ងៃហ្នឹងខ្ញុំ គ្រាន់ដឹងថា តាម៉ក តាសារឿន តែមិនដែលបានឃើញផ្ទាល់ភ្នែកមិនដែលទេ ។

វណ្ណៈ:	ចឹងឆ្នាំ១៩៩៣ហ្នឹង ប្តីមីងបានមកជួបជុំគ្នាវិញនៅឬអត់ទេ?

រី:	ចាស ។

វណ្ណៈ:	ឆ្នាំ១៩៩៣ ពេលមីងមកនៅក្នុងភូមិហ្នឹង ប្តីមីងមកពីសមរភូមិមកជួបជុំគ្នាវិញនៅ?

រី:	សព្វថ្ងៃនេះ ។

វណ្ណៈ:	កាលឆ្នាំ១៩៩៣ កាលមីងមកនៅក្នុងភូមិនេះ មីងបានជួបជុំប្តីឡើងមកពីសមរភូមិវិញរស់នៅជាមួយគ្នាហើយឬមួយមិនទាន់ទេ?

រី:	អូ!មកជួបជុំគ្នាចុះទៅសមរភូមិ បែកគ្នាចំនួនមួយខែអីចឹងមកនៅរហូតទាល់ឥឡូវហ្នឹងទៅប្តីខ្ញុំមកដាច់ជើងត្រឹម៩៥នេះ ។

វណ្ណៈ:	ចឹងឆ្នាំ៩៥ដាច់ជើង?

រី:	ចាស!៩៥ជិតផ្តាច់ខ្លួនយើងនេះហើយ ។

វណ្ណៈ:	ចឹងមីងមកនៅភូមិនេះបានជួបប្តីហើយ?

រី:	ចាស ។

វណ្ណៈ:	ចឹងប្តីមីងគាត់ឡើងមកតាំងពីឆ្នាំណា?

រី:	ប្តីខ្ញុំឡើងមកនៅជាមួយគ្នាដាច់ជើងត្រឹម៩៥ហ្នឹង នៅជុំគ្នារហូតទៅ ។

វណ្ណៈ:	ហ្នឹង៩៥ហើយតែខ្ញុំចង់ដឹងកាលឆ្នាំ៩៣ ឆ្នាំ៩៥ក្រោយទេ៩៣សម័យអ៊ុនតាក់ សម័យអ៊ុនតាក់ មីងមានបានបោះឆ្នោតទេកាលហ្នឹង?

រី:	អត់ទេ ។

វណ្ណៈ:	ចឹងអត់បានបោះទេ?

រី:	ចាស!មិនដឹងបោះយ៉ាងម៉េចទេ មិនដឹង ។

វណ្ណៈ:	ចឹងពេលអ៊ុនតាក់ចូលមកមីងមានដឹងទេ?

រី៖ ៩៣ជិនាន់អ៊ុនតាក់ខ្ញុំមកនៅហ្នឹងម្ដង នៅក្នុងភូមិហ្នឹង ភូមិចាស់តើនៅ និយាយរួមទៅបីសារទាំងហ្នឹងហើយ បាននៅហ្នឹងនរ ។

វណ្ណៈ៖ ចឹងមកដល់ហ្នឹងមានរត់ចុះឡើងទៀត?

រី៖ ចាស ។

វណ្ណៈ៖ ចឹងមីងមកនៅដំបូងហ្នឹង មីងនៅជាមួយប្ដីហើយ?

រី៖ មកនៅជាមួយប្ដីឆ្នាំ៩៣ហ្នឹង មកនៅមានទីកន្លែងនៅហើយក៏ប្ដីទៅសមរភូមិទៅបាត់ ។

វណ្ណៈ៖ ចឹងគាត់ទៅមកទៀត?

រី៖ ចាស! ទៅមកៗដូចថានៅសមរភូមិ ចំនួនមួយខែពីរខែអីមកម្ដងអីចឹង ។

វណ្ណៈ៖ ចឹងលែងយូរពេលដែលទៅកំពង់ធំហើយ?

រី៖ ចាស! កាលនៅកំពង់ធំ កាលហ្នឹងទៅបែកគ្នាយូរ ដល់ក្រោយមកនេះមកនៅឆ្នាំ៩៣ជិនាន់អ៊ុនតាក់ មកនៅហ្នឹងតែប្ដីទៅសមរភូមិមុខ តែគ្រាន់ទៅមកៗ ។

វណ្ណៈ៖ ចឹងចុះមកដល់ហ្នឹងហើយមានរត់ចុះឡើងច្រើនសារទៀត?

រី៖ ចាស ។

វណ្ណៈ៖ ចឹងក្រោយមកខ្មែរក្រហមមានការបែកបាក់ដូចជា តាម៉ុល ពត តាម៉ុក ចាប់កាត់ទោសអីមីងមានដឹងទេ?

រី៖ ដឹងតើ ។

វណ្ណៈ៖ មីងមានបានមកចូលរួមកាត់ទោសទេ?

រី៖ អត់ទេ ចាប់មេខាងខ្ញុំតាសារឿន តាសាន អីហ្នឹង ។

វណ្ណៈ៖ គេចាប់គាត់ដោយសារអីតាសាន តាសារឿន ហ្នឹង?

រី៖ ខ្ញុំមិនដឹងដែរ គេចាប់ទៅហ្នឹងមិនដឹងជាក្បត់អីយ៉ាងម៉េច ខ្ញុំមិនសូវដឹងដែរ គេថាចាប់ទៅៗ ។

វណ្ណៈ៖ ចឹងតាសុន សេន គេសម្លាប់ទាំងគ្រួសារហ្នឹង មីងមានដឹងទេ?

រី៖ អត់ទេ ខ្ញុំអត់ដឹងទេ មិនដឹងគេសម្លាប់នៅណា មិនដឹងចាប់នៅណាផង ។

វណ្ណៈ៖ ចឹងតាប៉ុល ពត មីងដឹងថាគេកាត់ទោសគាត់ តែក្រោយមកមីងមិនបានទៅចូលរួមទេ?

រី៖ អត់ទេ មិនងាយទេ ប្រជាជនយើងឆ្ងាយៗចេះមិនងាយបានចូលទេ ។

វណ្ណៈ៖ ចឹងក្រោយមកទៀតមីងមានដឹងទេថា ពីណាជាអ្នកនាំចូលជាមួយរដ្ឋាភិបាល ដើម្បីឲ្យកើតមានសមាហរណ៍កម្មមានសន្តិភាពដល់សព្វថ្ងៃនេះ មានដឹងទេ ថាពីណាគេកាលហ្នឹង?

រី៖ មិនដឹងពីណាខ្លះទេ តាមខ្ញុំដឹងមានតាហឿន អីមកនៅទទួលខុសត្រូវកន្លែងនេះ ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ	ចឹងមីងមានដឹងថា សមាហរណ៍កម្មកើតឡើងនៅឆ្នាំណា ដែលឲ្យយើងបានសុខ?
រី:	កាលរត់មកពីលើហ្នឹង ឆ្នាំ៩០ប៉ុន្មានទេ ៩៩ហ្នឹងហើយ ។
វណ្ណៈ	ចឹង៩៩?
រី:	ចាស!៩៩ កាលយើងផ្ដាច់ខ្លួន ៩៩ហ្នឹងហើយ ។
វណ្ណៈ	ចឹងតាំងពីហ្នឹងមកនៅសុខរហូតទៅ?
រី:	ចាស!តាំងពីហ្នឹងមកនៅនេះរហូត អត់មានទៅណាទៀតទេ ។
វណ្ណៈ	ចឹងពេលមកដល់មានស្រុកសន្តិភាពចឹង កូនចៅមីងមានបានរៀនសូត្រទេ?
រី:	បានរៀនដែលតែវាមិនបានជ្រៅជ្រះមួយៗ រៀនបានត្រឹមថ្នាក់ទី៤ថ្នាក់ទី៦អីចឹង ឥឡូវវាឈប់អស់ហើយ ឈប់រៀនអស់ហើយនៅតែអាពៅមួយ ។
វណ្ណៈ	ចឹងដោយសារមូលហេតុអីបានគាត់ឈប់រៀន?
រី:	មិនដឹងថា មូលហេតុអីបើវាមិនទៅ ប្រាប់ឲ្យវាទៅរៀនទៀតវាមិនទៅវាឈប់តែម្ដង តឿនហើយក៏មិនទៅនាំទៅក៏មិនទៅវាថាឈប់ហើយៗវានាំគ្នាឈប់ ប្រដាក់ៗអាបងនោះឈប់មុនគេ មើលថ្នាក់ទី៦ឆ្នាំ២០០០ប៉ុន្មានទេ ។
វណ្ណៈ	ចឹងមីងគិតថា ការរៀនសូត្រវាមានសារសំខាន់ដែលសម្រាប់ខ្លួនរបស់មីងទៅថ្ងៃអនាគត?
រី:	ចាស!រៀនសម្រាប់ខ្លួនឯង ម្ដាយឪពុកគិតចឹង តែចិត្តវា មិនដឹងជាវាគិតយ៉ាងម៉េចបើឲ្យវាទៅវាមិនទៅ ឪពុកម្ដាយតឿនដែរ ខ្ញុំនិយាយមិនថាម៉េច បើគេអ្នកក្រៅនិយាយថា មកពីម្ដាយ មិនដាស់តឿន ចំណែកម៉ែខ្ញុំនេះ តឿនថាមុនរៀនហ្នឹងយំរហេមរហាមចុះបើវារត់វាអីចេះតែវាយ ដួនកាលមាត់ថាខ្លះទៅ មិនស្ដាប់ទៅក៏ខ្វាំងខ្លះទៅវាអស់ពីល្អពេកវាមិនតាម ។
វណ្ណៈ	ចឹងតាមដំណើរ?
រី:	តាមដំណើរឈប់បន្តគ្នា ខ្ញុំចង់ឲ្យរៀនកូនឈប់រាល់គ្នា រៀនរាល់ថ្ងៃនេះឈប់ៗនេះខ្ញុំ ខ្ញុំថាបើឯងឈប់នេះ ទៅមុខៗទៀតៗអនាគតខ្លួនឯងរកស៊ីកុំបន្ទោសថាម៉ែ អូសទាញមិនឲ្យរៀនខ្ញុំអត់មានឃាត់ទេ តឿនណាស់ឲ្យរៀនកូន សព្វថ្ងៃក៏ដោយ ។
វណ្ណៈ	ចឹងមកដល់រាល់ថ្ងៃនេះមានមន្ទីរពេទ្យ សាលារៀន វត្តអារាមនៅក្នុងភូមិនេះ?
រី:	វត្តមានតែមួយកន្លែងហ្នឹង កសាងមិនទាន់បាមល្អទេ នៅខ្វះខាតនៅឡើយ ។
វណ្ណៈ	ចឹងមកដល់សព្វថ្ងៃនេះមីងកាន់សាសនាអីដែរ?
រី:	សាសនាខ្មែរហ្នឹង ។
វណ្ណៈ	សាសនាខ្មែរ សាសនាអីគេ?
រី:	ខ្មែរយើងរាល់ថ្ងៃនេះ ។

វណ្ណៈ៖ សាសនាព្រះពុទ្ធ?

រី៖ ចាស ។

វណ្ណៈ៖ ចឹងមីងយល់យ៉ាងម៉េចដែលយើងគោរពសាសនាព្រះពុទ្ធហ្នឹង នាំឲ្យយើងបានទទួលផលអីដែរតាមមីងគិត?

រី៖ ខ្ញុំមិនសូវដឹងទេ ខ្ញុំគ្មានចេះធម៌មួយម៉ាត់ផង ។

វណ្ណៈ៖ ចឹងមីងគិតថា សាសនាព្រះពុទ្ធហ្នឹងអាចនាំយើងទៅផ្លូវល្អមិនឲ្យប្រព្រឹត្តិអំពើអាក្រក់អីចឹង?

រី៖ ចាស!ខ្ញុំយល់ឃើញចឹងដែរ ។

វណ្ណៈ៖ ចឹងពេលទៅវត្តចឹង មីងមានបាយមួយចានសម្លមួយស្រាក់ហ្នឹង មីងមានគោលបំណងយ៉ាងម៉េចដែរ ពេលមីងធ្វើបាយសម្លទៅវត្តហ្នឹង?

រី៖ ចិត្តមានថាយ៉ាងម៉េច ផ្សងឲ្យជួយថែរក្សាឲ្យបានសុខ នឹកឃើញតែចឹង ។

វណ្ណៈ៖ ចឹងប្រទេសឈប់មានសង្គ្រាមនិងសម័យមានសង្គ្រាមណាស់ តើមួយណាមីងអាចរស់នៅស្រួលជាង?

រី៖ ប្រទេសសន្តិភាពសុខស្រួលហ្នឹងហើយ រឿងរត់លូនដឹងថាឆ្អែតឆ្អន់ហើយ ។

វណ្ណៈ៖ ចឹងឥឡូវស្រួលជាង?

រី៖ ចាស!ឥឡូវវាស្រួល កូនចៅឥឡូវបើដូចជំនាន់ពួកខ្ញុំនោះងាប់អស់ហើយ មិនមែនរស់ទេ ដូចថាវាពិបាកដែលណាក្មេងៗឥឡូវ ។

វណ្ណៈ៖ ចឹងជំនាន់ពីដើមដូចជាជំនាន់លន់ នល់ មានវត្តមានវ៉ាសម្រាប់គោរពចឹងដែរ ជំនាន់ លន់នល់ ជំនាន់សម្តេចសីហនុអីមានវត្តទេ?

រី៖ ខ្ញុំនៅក្មេងៗអីផ្ទះនោះមានដែលដល់ចូលក្នុងជួរមានបុណ្យមានទានអី មិនដែលមានវត្តអីនៅក្នុងខ្មែរក្រហម ។

វណ្ណៈ៖ ចឹងសម័យខ្មែរក្រហមអត់មាន?

រី៖ ចាស!អត់មាន ។

វណ្ណៈ៖ ចឹងឥឡូវមានវិញ?

រី៖ ចាស!ឥឡូវមានវិញ ។

វណ្ណៈ៖ ចឹងជីវភាពមីងកាលមុនសម័យខ្មែរក្រហមជួបកាលលំបាកដែលឬមួយយ៉ាងម៉េច?

រី៖ ពិបាកណាស់ កាលសម័យខ្មែរក្រហម ។

វណ្ណៈ៖ អត់ទេ សម័យខ្មែរក្រហមពិបាកហើយ តែមុនសម័យខ្មែរក្រហមកាលមីងហូបបាយតាមផ្ទះនោះ?

រីៈ ខ្ញុំអត់បានហូបបាយរួមអីនៅផ្ទះអត់បានផង ។

វណ្ណៈ ចង់និយាយជីវភាពមីងនៅជាមួយឪពុកម្ដាយ?

រីៈ នៅជាមួយឪពុកម្ដាយខ្ញុំពិបាកដែរ អត់សូវមានស្រែចម្ការផ្ទះសំបែងមិនទាន់មានល្អ ។

វណ្ណៈ ចឹងមកដល់សម័យឥឡូវនេះមីង ជីវភាពមីងប្រចាំថ្ងៃរាល់ថ្ងៃយ៉ាងម៉េចដែរ?

រីៈ ជាមធ្យមគ្រាន់ទប់ទល់ វាមិនលំបាកប៉ុន្មានទេ វាបានស្រួលមានស្រែចម្ការអីបានហូបបានធូរធារ បាយទឹកមិនចេះខ្វះទេ យ៉ាប់រឿងលុយចាយ វាពិបាកដែលរឿងឈឺគ្រុនវាពិបាកដូចថាយើងខ្វះខាតលុយកាក់អី យើងមិនសូវមានប្រាក់ចំណូល ។

វណ្ណៈ ចឹងនៅក្នុងស្រុកភូមិរបស់មីង ពួកគាត់ភាគច្រើនប្រកបមុខរបរអី ដាំអីភាគច្រើននៅក្នុងតំបន់ហ្នឹង?

រីៈ ចំរុះតាមចំណូល តាមចំណូលរបស់គេធ្វើតាមគ្រួសារ ខ្លះទៅគេធ្វើបើដូចខ្ញុំ សព្វថ្ងៃមានតែស្រែចម្ការ ហើយផុតពីចម្ការហ្នឹងប្រាំងយើងនេះកាប់ដាំរនោងខ្ញុំដាំរនោងបានបន្តិចបន្តួចទៅរួមផ្សំគ្នា អ្នកស្រុកអ្នកភូមិយើងខ្លះគេដាំសណ្ដែកទៅ មានតែដំឡូងមានតែស្រូវហ្នឹងឯង ។

វណ្ណៈ ចឹងមីងនៅពេលយើងភ្ជួរស្រែដាំស្អីៗហ្នឹង មីងមានដែលពិភាក្សាជាមួយគ្រួសារ ថាយើងឆ្នាំក្រោយដាំអី ឆ្នាំនេះត្រូវដាំអី ដែលនិយាយពិភាក្សាគ្នាដែលរឿងហ្នឹង?

រីៈ មាននិយាយតើ ពិភាក្សាគ្នាថាត្រូវធ្វើអីៗ ។

វណ្ណៈ ចឹងពិភាក្សាច្រើននៅពេលណា ពេលបាយសម្រាកពីការងារ?

រីៈ ពេលសម្រាកពីការងារអង្គុយនំនេរចឹង ឯងត្រូវធ្វើអីៗចឹងមាននិយាយគ្នាដែលហ្នឹង ។

វណ្ណៈ ចឹងចំពោះប្រពៃណីទំលាមទំលាប់អី កាលសម័យមុនខ្មែរក្រហម តើការស្លៀកពាក់របស់ស្ត្រីខ្មែរយើងរបៀបយ៉ាងម៉េច កាលហ្នឹងស្លៀកពាក់សមរម្យឬមួយយ៉ាងម៉េចដែរ?

រីៈ កាលនៅផ្ទុះកំណើតនោះ ។

វណ្ណៈ បាទ!ចង់និយាយរឿងប្រពៃណីពីដូនតា?

រីៈ នៅក្មេងៗដែលស្លៀកពាក់មានហឺហាប៉ុន្មានទេ មិនដូចគេក្រមុំកំលោះអីទៅ គេស្លៀកពាក់ដូចជាអាវប៉ាក់អាវអីហូរអីចឹងមាន តែកាលនោះខ្ញុំនៅក្មេងៗដែលមិនទាន់បានស្លៀកពាក់អី ។

វណ្ណៈ តែគ្រាន់ដឹងថា កាលស្លៀកពាក់សម័យនោះវាសមរម្យ?

រីៈ សមរម្យ ទៅបុណ្យទៅទានអី ។

វណ្ណៈ ចឹងសម័យខ្មែរក្រហមមានទេ ហូរប្រមូងអី?

រីៈ សម័យខ្មែរក្រហមមិនដែលឃើញទេ មានតែស្លៀកពាក់ខ្មៅ សម្លៀកបំពាក់ធម្មតាយើង ។

វណ្ណៈ	ចឹងមីងមកដល់សម័យឥឡូវក្មេងយើងរាល់ថ្ងៃនេះ កូនចៅយើងរាល់ថ្ងៃកាន់ទំលាមទំលាប់ប្រពៃណីស្លៀកពាក់អីហ្នឹង ដូចថាមានលក្ខណៈរម្យទុំដូចពីដើមដែលឬមួយយ៉ាងម៉េចឬមួយខុសប្លែកគ្នា?

រី:	ក្មេងឥឡូវដូចជាពិបាកថាដែរ ស្លៀកពាក់ដូចបានឃើញដែរ មិនថាស្រីមិនថាប្រុសទេ ស្លៀកពាក់លើសពីយើងឆ្ងាយណាស់ ។

វណ្ណៈ	ចឹងមីងសព្វថ្ងៃនេះចំពោះអ្នកជិតខាងយើងរាប់អានគ្នាយ៉ាងម៉េចដែរ?

រី:	រាប់អាននៅខ្មែរក្រហមជាមួយគ្នាហ្នឹង ធ្លាប់តស៊ូពីយូរមកនេះក៏រាប់អានរបៀបរបបរាល់ថ្ងៃនេះដូចជាបងប្អូនទៅហើយ ដូចថាវាឆ្ងាយពីម៉ែពីឪមកដូចថាញាតិជិតខាងនេះ យើងពឹងផ្អែកដូចជាបងប្អូនទៅហើយ ព្រោះអីយើងធ្លាប់តស៊ូលំបាកលំបិនជាមួយគ្នាមក មកនៅចេះក៏មិនដែលមានទំនាស់ទាស់ទែងជាមួយគ្នារាប់អានគ្នាធម្មតារាល់ថ្ងៃ ។

វណ្ណៈ	ចឹងបើធ្វើការប្រៀបធៀបគ្នាពីសម័យតស៊ូហើយឥឡូវវាមានភាពខុសគ្នាខ្លះដែរ?

រី:	ចាស ។

វណ្ណៈ	សម័យតស៊ូដែលយើងនៅក្នុងព្រៃ ហើយមកដល់សម័យយើងមានលុយចាយចឹង តើមានភាពខុសគ្នាខ្លះដែលឬយ៉ាងម៉េច?

រី:	មានខ្លះដោយបុគ្គលដែរ ខ្លះគេមានចាយមានអីចឹងទៅ ក៏មានឆ្មើងឆ្មៃហ្នឹងយើងខ្លះដែលណាវាមិនមានល្អទាំងអស់ទេ ។

វណ្ណៈ	បាទ ។

រី:	យើងរាប់អានគ្នាធម្មតាទៅ លំបាកលំបិនទាំងអស់គ្នា ខ្លះមានទៅដែលមិនធ្លាប់មាន ដល់មានវាងឆ្មើងខ្លះដែរ ។

វណ្ណៈ	ចឹងមីងធ្លាប់ឆ្លងកាត់កន្លងមកហ្នឹង មីងមានដែលឃើញគេចាប់មនុស្សឬគេវាយធ្វើទារុណកម្មមនុស្សដោយប្រការណាមួយដែរ លើនរណាម្នាក់ដែរ មីងមានធ្លាប់ឃើញគេធ្វើបាបមនុស្សទេ?

រី:	សម្លាប់ចោលអី មិនដែលបានឃើញទេ ។

វណ្ណៈ	ចឹងមិនដែលបានឃើញទេ?

រី:	ចាស ។

វណ្ណៈ	ចឹងបានដឹងថា ស្លាប់ដោយសារជំងឺស្លាប់ដោយសារសង្គ្រាម?

រី:	ចាស!ស្លាប់ដោយសារជំងឺ ស្លាប់ដោយសង្គ្រាមពុកគេថាស្លាប់លើអីខ្លះទេ ។

វណ្ណៈ	ចឹងកាលសម័យសង្គ្រាមហ្នឹង មីងមានឃើញគេចាប់ឈ្លើយសឹកណា ចាប់យកមកធ្វើបាបមីងមានដែលបានឃើញទេ?

រីៈ	ឃើញគេចាប់មក តែមិនដឹងជាមេៗយកទៅខាងណា ខ្ញុំមិនបានដឹងដែរ គ្រាន់ឃើញថា ចាប់បានឈ្លើយសឹក ។

វណ្ណៈ	ចឹងឃើញចាប់បានយួន ចាប់បានទាហានខាងរដ្ឋកម្ពុជាអីចឹង?

រីៈ	ចាស! តែមិនដឹងថាគេយកទៅខាងណា ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ	ចឹងមីងរាល់ថ្ងៃហ្នឹង មីងមានដែលបានទៅលេងស្រុកកំណើតទេ?

រីៈ	ទេ បានម្ដងដែលតាំងពី២០០២មក ។

វណ្ណៈ	ចឹងមកដល់ឥឡូវមីងមានចិត្តចង់ទៅរស់នៅស្រុកកំណើតវិញទេ?

រីៈ	នឹកឃើញចង់ដែលតែខ្វះខាតលុយកាក់ អត់មានលុយកាក់ដើរ កូនចៅច្រើនវាខ្វះខាតលុយកាក់ ។

វណ្ណៈ	ចឹងបងប្អូនមីងមកនៅជាយដែនហ្នឹងប៉ុន្មានគ្រួសារដែរ?

រីៈ	មកពីស្រុកតែពីរនាក់ប្អូនហ្នឹង ប្អូនមកហ្នឹងដោយសារតែប្ដីដែរ ប្ដីធ្វើបាបពេកក៏រត់បែកបាក់គ្នា មកតាមខ្ញុំ ។

វណ្ណៈ	ចឹងគាត់មានកូនចៅដែរ?

រីៈ	មានកូនតែពីរទេ ។

វណ្ណៈ	ចឹងប្ដីមានមកតាមទេ?

រីៈ	ប្ដីលែងលះគ្នា ឥឡូវឮថាស្លាប់បាត់ហើយ មកតាំងពីឆ្នាំប៉ុន្មាន តាំងពីខ្ញុំផ្ដាច់ខ្លួនហ្នឹង ។

វណ្ណៈ	ចឹងមីងបញ្ហាដីធ្លីរាល់ថ្ងៃមានប៉ះពាល់ជាមួយក្រុមហ៊ុនគេមករឹបអូសដែរ?

រីៈ	កាលឆ្នាំ២០០២-២០០៣ កាលនោះមានម្ដងដែរ ទាហានអីមក ក្រោយមកដោះស្រាយបានមកវិញ បានស្រែចម្ការធ្វើវិញ ។

វណ្ណៈ	ចឹងមីងរាល់ថ្ងៃហ្នឹង បើសិនជាយើងមានរឿងរ៉ាវទំនាស់ដីធ្លីអីហ្នឹង ឬមានបញ្ហាអីមួយមីងអាចពឹងពាក់ទៅលើច្បាប់ មីងអាចជឿជាក់បានទេ ច្បាប់យើងរាល់ថ្ងៃហ្នឹង?

រីៈ	ខ្ញុំអត់មានបះពាល់អីផងដីខ្ញុំ ។

វណ្ណៈ	តែឧទាហរណ៍ បើយើងមានរឿងរ៉ាវអី?

រីៈ	ខ្ញុំមានម្ដងដោះស្រាយរួចមួយសារហើយដីស្រែ ។

វណ្ណៈ៖ ចឹងមីងគិតថាច្បាប់រាល់ថ្ងៃហ្នឹងអាចទទួលយកបានដែលទេឬមួយនៅខ្វះខាត ច្បាប់យើងរាល់ថ្ងៃហ្នឹង បើមានរឿងអ្វីផ្ដល់យើងអាចទៅពឹងពាក់ជាមួយអាជ្ញាធរឬជាតុលាការអីចឹង មីងអាចទុកចិត្តបានដែរឬក៏មិនទេ?

រី៖ មិនដឹងជាថាយ៉ាងម៉េចបើមិនដែលបានទៅ ខ្ញុំខ្វះខាតខាងទ្រឹស្ដីខ្ញុំមិនសូវចេះរៀបរាប់ទេ ។

វណ្ណៈ៖ ចឹងរាល់ថ្ងៃបើសិនជាមានជនអន្តោប្រវេសហ្នឹង សំដៅទៅលើប្រទេសជិតខាងឬមួយជាជនជាតិផ្សេង គេមករស់នៅក្នុងភូមិមីងដែរ តើមីងសប្បាយចិត្តទេ?

រី៖ មិនដឹងជាយ៉ាងម៉េច ។

វណ្ណៈ៖ ឥឡូវឧបមាថា យួន វៀតណាម ថៃ គេមករស់នៅក្បែរភូមិមីងចឹង រស់នៅភូមិជាមួយមីងដែរ មីងសប្បាយចិត្តទេ?

រី៖ មិនសប្បាយទេ ប្រទេសមកនៅចឹង វារឹបជាន់យកដីយើងហ្នឹងឯង យកប្រទេសកម្ពុជា ។

វណ្ណៈ៖ ចឹងមីងមិនសប្បាយទេ?

រី៖ ចាស ។

វណ្ណៈ៖ ចឹងខ្មែរគ្នាឯង?

រី៖ ខ្មែរគ្នាឯងធ្លាប់តស៊ូមានអី សព្វថ្ងៃដោយសាររឿងដីហ្នឹង ថៃនិងយើងខ្មែរនេះ បន្តិចចេះបន្តិចចុះភ័យ ភ័យតែរហូតនៅជើងភ្នំ ។

វណ្ណៈ៖ ចឹងកាលមីងមកដល់ដំបូងមានព្រៃឈើច្រើន?

រី៖ អ៊ូស!នៅសនះសុទ្ធតែព្រៃ នេះសុទ្ធតែដាំណាំយើង បើមុនៗសុទ្ធតែព្រៃ មកកាប់តែមួយកន្លែងនៅសិន កាប់ម្ដងបន្តិចៗ ទំរាំបានកើតស្រែកើតចម្ការ ទំរាំមានរបស់ប្រើ ។

វណ្ណៈ៖ ចឹងឥឡូវព្រៃឈើចង់អស់ហើយ?

រី៖ អូស!ស្រឡះល្វឹងល្វើយហើយ ឡើងស្រែចម្ការអស់ហើយ ។

វណ្ណៈ៖ ចឹងអត់មានកូនចៅបានមើលដើមឈើធំៗទៀតទេ?

រី៖ អត់ទេ កាប់អស់ហើយ ។

វណ្ណៈ៖ ចឹងខ្ញុំដូចជាអស់អីសួរមីងហើយ មីងបានចំណាយពេលជាងមួយម៉ោងដែរ ចឹងមីងមានចង់និយាយបន្ថែមទៀតដែរ?

រី៖ ខ្ញុំមិនដឹងមានអីទេ ។

វណ្ណៈ៖ ចឹងខ្ញុំអរគុណមីងច្រើនហើយ ។

រី៖ ចាស ។

**ចប់**